# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភិយ-ប៊ុក ក្រមការ
នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ស្វរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

| *ផ្នែកអក្សរសាស្ត្រ* | បញ្ជីរឿង | ទំព័រ |
| --- | --- | --- |
| អ្នកឧកញ៉ា ឈឹម-ក្រសេម | ព្រះរាជពង្សាវតារភាគទី ២ (សម័យឧដុង្គ)... | ៨៨៩ |
| លោក ភិយ-ប៊ុក ក្រមការ | សុភាសិតខ្មែរភាគទី ២ (តទៅ-ចប់)......... | ៨៩១ |
| ឃុនសិរីមេធី ស្រី-អ៊ូ | បណ្ដាំមាតា (តទៅ-ចប់) ................ | ៨៩៧ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ស័ព្ទបារាំងប្រែជាខ្មែររបស់គណៈកម្មការវប្បធម៌ (តទៅ)............................ | ៩០៦ |
| — | ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា (តទៅ-ចប់) | ៩១៣ |
| ឧកញ៉ា នូរ-កន | រឿងសាមកុក (តទៅ) ................ | ៩២១ |
| *ផ្នែកសាសនា* | | |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក ថែម | ប្រវត្តិព្រះអានន្ទត្ថេរ ...................... | ៩៣៥ |
| — | ច្បាប់ក្រមសាមណេរ ...................... | ៩៤០ |
| *ពាក់ទីនប្រវត្តិការណ៍* | | |
| ប្រ.ប្អូនធម្មការ | បញ្ជីភយនាមចៅអធិការដែលតាំងថ្មី (តទៅ)... | ៩៤៨ |
| លោក ភិយ-ប៊ុក ក្រមការ | កំណត់ស្មើអំពីរឿងស្ថាបនាវិទ្យាស្ថានទួយសម្រាប់សិក្សាភាសាខ្មែរ ឥណ្ឌា នៅភ្នំពេញ...... | ៩៥៨ |

ឆ្នាំទី ២០ — លេខ ១២ ខែធ្នូ ឆ្នាំ ១៩៤៨ — ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

# សម័យនគរធំ

អ្នកឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

# សេចក្ដីថ្លែងការណ៍

ព្រះរាជពង្សាវតារកម្ពុជាទាំងមូល ត្រូវចាត់ជាភាគជាសម័យដូចមានពោលហើយក្នុងភាគទី ១ សម័យនគរតូចនោះ ឥឡូវនេះនឹងបានសំដែងក្នុងភាគទី ២ សម័យនគរធំតទៅ ៗ ក្នុងសម័យនេះ ត្រូវគិតពីរជ្ជកាលព្រះបាទជយវរ្ម័នទី ២ (យមេស្វរៈ) ដល់រជ្ជកាលព្រះបាទជយវរ្ម័នយមេស្វរៈ គឺ ព. ស. ១៣៤៥ ដល់ ១៨៨១ រាប់ជាសម័យនគរធំ ៗ

ឯព្រះរាជពង្សាវតារ ដែលគេហៅឈ្មោះថា "ព្រះរាជពង្សាវតារក្រុងកម្ពុជា" ច្បាប់ចាស់ ៗ ទាំងប៉ុន្មាន ដែលនិយាយពីប្រវត្តិសាស្ត្រក្នុងសម័យនគរធំ យើងពិនិត្យទៅឃើញពិរុទ្ធជាច្រើនប្រការ គឺ

ក – ខុសរៀងទុកដាក់សម័យនគរធំ ជាបឋមសម័យ

ខ – ខុសរៀងប្រើសករាជ ឥតមានត្រូវបន្តិចសោះ

គ – ខុសរៀងហៅព្រះនាមស្ដេច ឥតមានត្រូវតាមសិលាចារិកដល់ ១ អង្គសោះ

ឃ – ខុសត្រង់ថ្លៃរឿងព្រះរាជពង្សាវតារនោះ ច្រើនពណ៌នាទៅជារឿងព្រេង រឿងបាដិហារ្យផ្សេងៗ សឹងល្វែងចេញពីរឿងពិតយ៉ាងឆ្ងាយ គួយ៉ាងដូចរឿងព្រះថោង រឿងព្រះកេតុមាលា រឿងសាង់នគរធំនគរតូច គឺនគរវត្តជាដើម នឹងយកជាខ្លឹមសារសូម្បីតែបន្តិច ក៏ពុំបានឡើយ ។

កាលរៀបរៀងព្រះរាជពង្សាវតារ ភាគទី ២ សម័យនគរធំគ្រានេះ ដោយអាស្រ័យតម្រាប់តម្រាថែបផែនផ្សេងៗ ជាគ្រឿងប្រកប គឺ:

១ – សិលាចារិករបស់ខ្មែរយើងដែលលោកបានចារិកទុកតាំងពីក្នុងសម័យនោះមក សឹងមានចំនួនជាច្រើន សិលាចារិកទាំងនោះ ជាប់ជាគោលសំខាន់បំផុត ក្នុងការរៀបរៀងប្រវត្តិសាស្ត្រខ្មែរ ។

២ – បុរាណវត្ថុស្ថាន នឹងឈ្មោះស្រុកខ្លះ ដែលគង់នៅដល់សព្វថ្ងៃនេះ ជាប់ជារបស់សំខាន់ សម្រាប់ប្រៀបធៀបប្រវត្តិសាស្ត្របាន ១ យ៉ាងទៀត ។

៣ – ពង្សាវតារ - សេចក្ដីកត់ហេតុរបស់ចិន (ជូណាង ណ័រតៀជូ) ដែលបានទាមទារដល់ពង្សាវតារខ្មែរ ដែលអ្នកប្រាជ្ញប្រវត្តិសាស្ត្រ ជាតិបារាំងបានប្រែស្រង់ចេញជាភាសាបារាំងមកហើយ ។

៤ – សេចក្ដីអធិប្បាយពីបុរាណស្ថានផ្សេងៗ របស់ខ្មែរយើងដែលអ្នកប្រាជ្ញបារាំង មានលោក ល្វី - ហ្វីណូត៍ នឹងលោក ហ្សក-សឺដេស

ជាដើម បានអធិប្បាយទុក សឹងមានប្រែជាភាសាខ្មែរ សឹងមានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ក្នុងឆ្នាំផ្សេង ៗ ខ្លះហើយ ។

៥ - ប្រវត្តិសាស្ត្រសាកល របស់ហ្វង់រ៉ិចត្រហ្វទការ, និង

៦ - ប្រវត្តិព្រះកែវមរកត ( ខ្មាម ឡុប ១ង ព្រះកែវមរកត ) របស់អយ៉ណាឃោស ។ ល ។

សេចក្ដីពិត ព្រះរាជពង្សាវតារក្រុងកម្ពុជាសម័យនគរធំរបស់យើងគ្រប់ ៗ ច្បាប់ដែលមានមកហើយ គួរបានជាទីអាស្រ័យយ៉ាងច្រើនតែម្ដងតែនេះមិនដូច្នេះ ត្រឡប់ជាអាស្រ័យបានយ៉ាងតិចជាបំផុត ទាំងនេះដោយហេតុព្រះរាជពង្សាវតារសម័យនោះ ដ៏ជារបស់ចាស់ជាន់ដើមហើយជារបស់ដែលត្រឹមត្រូវពិតប្រាកដនោះ បានសាបសូន្យទៅយូរហើយ នៅមានសេសសល់ខ្លះ តែដោយសិលាចារឹក និងសេចក្ដីកត់ហេតុរបស់ជាតិដទៃ, ព្រះរាជពង្សាវតារក្រុងកម្ពុជាបណ្ដាដែលមាននៅក្នុងបច្ចុប្បន្ននេះ សុទ្ធតែជារបស់ដែលគេរួបរួមឡើងក្នុងសម័យក្រុងឧត្តុង្គនេះឯង ខនេះ អ្នករៀបរៀងឯង បានបញ្ជាក់ទុកនៅទំព័រខាងដើមថាខ្ញុំនរួបរួមឡើងដោយអាស្រ័យស៊ើបសួរអ្នកចាស់ព្រឹទ្ធាចារ្យទាំងឡាយដែលមាននៅក្នុងពេលនោះ ។ ព្រោះតែខ្លះសេចក្ដីស្រាវជ្រាវជាច្រើនដូច្នេះហើយ ព្រះរាជពង្សាវតារក្រុងកម្ពុជា សម័យនគរធំគ្រប់ ៗ ច្បាប់ទើបប្រាកដមានសេចក្ដីខុសគ្នាជាច្រើនអន្លើ ដូចពោលមកហើយ ។

ការរៀបរៀង ព្រះរាជពង្សាវតាររបស់ខ្ញុំក្នុងគ្រានេះថ្វីបើខ្ញុំបានស្រាវជ្រាវមកជាយូរឆ្នាំ គឺបានពិនិត្យមើលសិលាចារឹកខ្លះ ព្រមទាំងការពិនិត្យពង្សាវតារសេចក្ដីតក់ហេតុរបស់ជាតិជិតខាង ដោយសព្វគ្រប់មកហើយក៏ពិត តែក៏នៅតែមិនបានសេចក្ដីល្អិតល្អសព្វគ្រប់នៅឡើយ គឺបានត្រង់នេះ នៅខ្វះត្រង់នោះ បានត្រង់នោះនៅខ្វះត្រង់នេះ សឹងមានជាដរាប ដូចមានប្រាកដក្នុងព្រះរាជពង្សាវតារដែលខ្ញុំរៀបរៀងនោះហើយ ក្នុងខនេះខ្ញុំគោងញ៉មចុះចាញ់ហើយ ដោយហេតុបាផុតវិស័យរបស់ខ្ញុំនឹងស្រាវជ្រាវឲ្យបានសព្វគ្រប់ដូចបំណង ៗ ទោះបីដូច្នោះក៏ដោយ ត្រង់សេចក្ដីដែលខ្ញុំបានលិខិតទុកហើយ ខ្ញុំអាចនឹងរ៉ាប់រងថាមានខ្លឹមសារជាច្រើន ប្រៀបដូចរូបភាពដែលគេគូរព្រាសទុក ចម្លងរូបភាពដែលហៅថា គំនូរព្រាស ( គឺគំនូរព្រាង ) មិនដែលមានលក្ខណៈ ល្អិតល្អសព្វគ្រប់ទេ តែបើពិនិត្យគំនូរព្រាសនោះទៅដោយហ្មត់ចត់ហើយ គង់យល់បាន ថារូបភាពនោះជាអ្វី ៗ

ដោយហេតុ ប្រការខ្វះផុតវិស័យរបស់ខ្ញុំដូច្នេះ ក្នុងទីបំផុតនេះ ខ្ញុំទើបសូមស្នើឲ្យអ្នកសិក្សាប្រវត្តិសាស្ត្ររបស់ជាតិ ជួយស្រាវជ្រាវតទៅ ៗ ខ្ញុំមានសេចក្ដីសង្ឃឹមទុកថា ប្រវត្តិសាស្ត្ររបស់ជាតិយើង ដែលនឹងត្រឡប់មានសេចក្ដីបរិបូណ៌ឡើងវិញបានក៏ដោយអាស្រ័យអ្នកសិក្សាប្រវត្តិសាស្ត្ររួមគំនិតជាមួយខ្ញុំ ជួយស្រាវជ្រាវតទៅផង ៗ

# ព្រះបាទជ័យវរ្ម័ន ទី ២

**ព.ស. ១៣៤៥-១៤១២ — គ.ស. ៨០២ ៨៦៩**

ព្រះជ័យវរ្ម័នអង្គនេះ ជាព្រះរាជវង្ស ១ អង្គ ក្នុងអំបូររាជវង្សវរ្ម័នដែរ តែមិនប្រាកដថាជារាជឱរសរបស់ក្សត្រិយ៍អង្គណា ។

ក្រោយដែលព្រះបាទភាណុទិត្យវរ្ម័នទ្រង់ធ្វើសឹកបរាជ័យចាញ់ដៃជ្វា ហើយព្រះអង្គជ័យវរ្ម័នទ្រង់ឈឺចាប់ក្នុងព្រះហ្ឫទ័យជាបំផុត ព្រោះរឿងនេះ, ទោះបីព្រះអង្គមិនបានទទួលខុសត្រូវ ដោយចំពោះ ក៏ពិត តែក្នុងឋានៈព្រះអង្គជាខ្មែរ មានសេចក្តីស្នេហាជាតិពេញបន្ទុក ទាំងជាខត្តិយ-ជាតិ គឺជាអ្នកបំប៉ាងរបស់ជាតិមក ឃើញសេចក្តីបរាជ័យយ៉ាងងាយៗ នៅមុខដូច្នេះ ទ្រង់ក៏ទ្រាំនៅស្ងៀមតទៅពុំបាន តែងស្តេចភៀសចេញអំពីស្រុក ទៅកាន់ប្រទេសជ្វា ដើម្បីស៊ើបឱ្យពិនិត្យមើលកំឡាំងជ្វាឲ្យជាក់ ដោយព្រះនេត្ររបស់ព្រះអង្គ, បានស្តេចយាងទៅដល់ក្រុងស្រីវិជ័យ ដ៏ជារាជធានីរបស់ជ្វា និងនៅស្រុកសំខាន់ៗ ដទៃទៀតជាច្រើនអន្លើ ក្រោយបំផុត បានស្តេចមកស្នាក់នៅស្រុកប័នដុង នៅឆ្នេរទន្លេប័នដុង អស់វេលា ៤ - ៥ ខែហើយក៏ស្តេចត្រឡប់មកព្រះនគរវិញ ។

វេលាស្តេចដល់ព្រះនគរហើយ ទ្រង់ព្រះចិន្តាថា តស៊ូក្រោករបស់ជាតិជារបស់មានដំឡៃជាងអ្វីៗ ទាំងអស់ ហើយជាមុខងាររបស់ជាតិសឹងមានក្សត្រិយ៍ជាប្រមុខ និងគប្បីស្ងួនជាងជីវិតរបស់ខ្លួនទៅទៀត ។

ការដែលនឹងរក្សាឥស្សរភាពទុកបាន ពោលទៅតាមសម័យដែលនិយម សម្បូណ៌សិទ្ធិរាជ ក៏ដោយមានព្រះមហាក្សត្រិយ៍ដែលទ្រង់មានព្រះសមត្ថភាព និងព្រះឥទ្ធិពលដ៏បរិបូណ៌ ។ ក្នុងខនេះ សមដូចព្រះរាជបន្ទូលដែលគេបានចារិកទុកនៅស្តុកក្តុម ក្នុងស្រុកស្រីសោភ័ណ ថា "...... ដើម្បីកុំឲ្យកម្ពុជទេសនេះ អាយ័តតថ្កាលេយ លេងអាច គឺក្រមគេងនៃផ្ទៃក្រោម គដាបក្រពត្តិ" នេះជាព្រះរាជយោបល់ នឹងព្រះរាជបានៃព្រះជយវរ្ម័ន ។

បន្ទាប់មកក្នុងរឿងដោះស្រាយបញ្ហាអាយ័តថ្កានោះ ទ្រង់យល់ថាត្រូវបំពេញកិច្ចជា ២ ផ្លូវដូច្នេះ ។

១ - ត្រូវធ្វើសឹកក្នុងប្រទេសពោលគឺ ធ្វើបរិវត្តន៍ទម្លាក់ស្តេចដែលទ្រង់រាជ្យសព្វថ្ងៃចេញពីរាជបល្ល័ង្ក ព្រោះទ្រង់ខ្សោយព្រះសមត្ថភាពណាស់ មិនអាចការពារឥស្សរភាពរបស់ជាតិឲ្យគង់នៅបាន ។

២ - ត្រូវទទួលរំដោះធ្វើសឹកនឹងប្រទេសក្រៅ ពោលគឺផ្កាមួយផ្លូវទៀតជាខាងក្រោយ ។ បើអាចតាំងពីរផ្លូវនេះ ឥស្សរភាពរបស់ខ្មែរអាចនឹងមានជីវិតឡើងវិញបាន ។ ក្នុងរឿងនេះ ព្រះជ័យវរ្ម័ន ទ្រង់ប្តេជ្ញាថា ៖ ក្នុងជីវិតរបស់ព្រះអង្គត្រូវតែស្រោចស្រង់មាតុភូមិ ឲ្យរួចអំពីអាយ័តរបស់ជាតិដទៃ បើមិនសម្រេចទេ សូម្បីជីវិតរបស់ព្រះអង្គនឹងសូន្យទៅក៏តាមការ ។ អំពីនោះ ទ្រង់ក៏ផ្តើមប្រមូលសេនាទាហាន

អំពីតំបន់ផ្សេងៗ តាមដែលប្រាកដឈ្មោះ គឺអំពីក្រេស្ដបុរៈ (ប្រាសាទក្ដិ-ប្រាកសេ) អំពីកម្ពុបុរៈ (ក្រចេះ) អំពីឥន្ទ្របុរៈ (ត្បូងឃ្មុំ) អំពីវ្យាធបុរៈ (បាភ្នំ) រួមបានជាកងទ័ពធំមួយៗ គ្រានោះ មានមន្ត្រីតូចពីរនាក់ (មិនប្រាកដឈ្មោះ) នៅនគរបុរី (ព្រៃកប្បាស) ជាអ្នកមានគុណវុឌ្ឍិ បានមកក្រាបទូលសូមយកអាសាផែនដី, ព្រះជ័យវរ្ម័ន ទ្រង់ទទួលមន្ត្រីទាំងពីរនេះនាំទុកជាសេនារបស់ព្រះអង្គ ៗ កាលប្រជុំសេនាទាហានបានគួរល្មមហើយ ស្ដេចក៏លើកទៅលុកក្រុងឥន្ទ្របុរៈ(១) ធ្វើការបដិវត្តន៍ទម្លាក់ព្រះបាទតាលាវិក្រមវរ្ម័ន ចេញពីរាជបល្ល័ង្ក បានសម្រេច ហើយព្រះអង្គក៏ឡើងគ្រងពិភពផែនដី ក្នុងឆ្នាំ ព. ស. ១៣៤៥ (ម. ស. ៧២៥) នោះទ្រង់មានព្រះអគ្គមហេសី ព្រះនាម "កម្ពុជាលក្ស្មី" ក្រោយមកទ្រង់មានព្រះរាជឱរស ១ អង្គ ព្រះនាមដើមដូចម្ដេច មិនប្រាកដ តែកាលព្រះរាជឱរសបានសោយរាជ្យក្នុងវេលាក្រោយមក ប្រាកដព្រះបរមនាមថា ជ័យវរ្ម័ន ដូចព្រះរាជបិតា ៗ

## សង្គ្រាមជ្វាគ្រា ទី ២

ក្នុងទីដែលត្រាស់ថា គោងធ្វើសង្គ្រាមនឹងប្រទេសជ្វានោះ ទៅសេចក្ដីពិតឥតល្បៀង គឺកាលក្សត្រិយ៍ជ្វាប្រាប់ថា ប្រទេសកម្ពុជាផ្លាស់

---

(១) ក្រុងនេះនៅខាងជើងទន្លេសាប គឺក្រុងដែលក្នុងព្រះរាជពង្សាវតារកម្ពុជាហៅថា ឥន្ទបត្តបុរី តែមិនមែនអង្គរធំ ។

ព្រះរាជាម្ចាស់ផែនដី ក៏ចាត់រាជទូតឲ្យមកផ្ដៀងថា ប្រទេសកម្ពុជាត្រូវនៅក្រោមបង្គាប់ប្រទេសជ្វាដូចក្នុងរជ្ជកាលមុន ។ ព្រះបាទជយវរ្ម័នត្រាស់តបរាជទូតជ្វាដោយព្រះរាជឱង្ការសូរសីហនាទថា សំដីដែលថា ប្រទេសកម្ពុជាត្រូវនៅក្រោមបង្គាប់ប្រទេសជ្វានោះ អាចមានបាន បំពោះតែក្នុងរជ្ជកាលមុន មួយពេលប៉ុណ្ណោះ, សម្រាប់រជ្ជកាលបច្ចុប្បន្ន មិនត្រូវការនឹងពុំសំឡេងបែបនេះទៀតទេ សូមកុំឲ្យជ្វាសង្ឃឹម យ៉ាងដែលធ្លាប់សង្ឃឹមនោះតទៅទៀតឡើយ ។ រាជទូតជ្វាបានស្ដាប់ព្រះរាជឱង្ការដូច្នោះ ក៏ក្រាបថ្វាយបង្គំលាត្រឡប់ទៅវិញ យកសេចក្ដីក្រាបទូលស្ដេចជ្វា តាមព្រះរាជតម្រាស់នោះគ្រប់ប្រការ ។ ព្រះរាជាជ្វាទ្រង់ព្រះសណ្ដាប់ហើយ ក៏ឈឺក្នុងព្រះរាជហឫទ័យ ហាក់ដូចអសិរពិសដែលគេប្រហារត្រូវកណ្ដាលខ្លួន ទើបត្រាស់ព្រះសូរសៀងយ៉ាងសីហនាទថា ត្រូវកម្រាបកម្ពុជាឲ្យខ្ទេច ! ហើយក៏ត្រាស់ឲ្យសេនាបតី ត្រូវបោះពលមកពេមរុកលុកកម្ពុជរដ្ឋ ដោយបំណងនឹងកំទេចឲ្យល្អិតលើសពីកាលមុន បំណែកព្រះអង្គ ក៏ទ្រង់តំណែងជាស្ដេចសឹក នាំទ័ពតាមផ្លូវជើងទឹកចូលមកប្រទេសកម្ពុជាពីខាងត្បូង ។

ព្រះបាទជយវរ្ម័នកាលទ្រង់ជ្រាបពត៌មានសឹកជ្វា លើកមកដល់ជាយព្រះរាជអាណាខែត្រហើយ ក៏ត្រាស់ឲ្យប្រជុំគណៈសេនាធិបតី ដើម្បីជាដំណឹងក្នុងផ្លូវការ នឹងត្រាស់ឲ្យសេនាបតីយុទ្ធនាធិការរៀបក្បួន

ទ័ពដោយស្រពន់ បំណែកព្រះអង្គក៏ទ្រង់តំណែងជាក្សត្រិយ៍សឹក លើកទ័ពហ្លួងទៅកំចាត់បច្ចាមិត្រ ។

សង្គ្រាមគ្រានេះ បើគិតតាមចំនួនរេហ៍ពល និងកម្លាំងពលរបស់ប្រទេសទាំងពីរ ត្រូវទុកជាសង្គ្រាមធំ ១ ក្នុងប្រវត្តិសាស្ត្រ ព្រោះប្រទេសទាំងពីរជាមហាប្រទេស មានកម្លាំងពលប្រហែល ៗ គ្នា ហើយការដែលកើតសង្គ្រាមគ្រានេះ ក៏ដោយមានសេចក្តីអាឃាតយ៉ាងខ្លាំងទាំងសងខាង តែខាងជ្វាបានស្មានទុកថា គង់ជាឈ្នះខ្មែរដូចលើកមុន ៗ ឯខាងខ្មែរ គេអាចទុកចិត្តបានថា ព្រះបាទជ័យវរ្ម័នជាក្សត្រិយ៍សឹកដ៏ឯក ដោយទ្រង់មានព្រះសមត្ថភាពក្នុងយុទ្ធសាស្ត្រ និងសេចក្តីក្លាហានពេញទី ៗ ឯសេនាទាហានរបស់ព្រះអង្គសោត ក៏សុទ្ធតែមានវិន័យមានសេចក្តីក្លាហាននិងសេចក្តីសាមគ្គី-ភក្តីចំពោះព្រះអង្គដ៏ចំហុត, ដោយហេតុនេះកាលកងទ័ពទាំងពីរខាងលើកទៅដល់ទល់មុខគ្នាហើយ ក៏បានតយុទ្ធគ្នាយ៉ាងអង់អាចតែមិនយូរប៉ុន្មាន កងទ័ពខ្មែរក៏សង្កត់កងទ័ពជ្វាជាប់ ដោយខាងខ្មែរមានចតុរង្គសេនាគ្រប់ទាំង ៤ ពួក ឯជ្វាមានតែពលថ្មើរជើងមួយពួក បានកាប់សម្លាប់ពលជ្វា និងចាប់បានទូកចំបាំងជ្វាច្រើនជាអនេក, ក្សត្រិយ៍ជ្វា និងរេហ៍ពលដែលសល់ពីត្រូវអាវុធស្លាប់ ក៏នាំគ្នារត់ចុះទូក ថយត្រឡប់ទៅវិញ ទាហានខ្មែរក៏ចុះទូកចំបាំងជ្វាដែលចាប់បាន បំផាយដេញតាមទៅរហូតផុតដែនមាលយូ ដែលពេលនោះជាដាយអាណាខេត្រនៃ

ប្រទេសកម្ពុជា ទើបត្រឡប់មកវិញ ។ ព្រះរាជបំណងរបស់ព្រះបាទជយវរ្ម័ន ទី ២ ឈ្មោះថា បានសម្រេចហើយក្នុងពេលនេះ ។

ការផែនដី: ជាទំនៀម ព្រះមហាក្សត្រិយ៍ខ្មែរពល់ៗ ព្រះអង្គតាំងអំពីដើមមក កាលទ្រង់ធ្វើព្រះរាជសង្គ្រាមមានជ័យជំនះហើយ តែងតែទ្រង់សាងឋានទី ឬវត្តសំខាន់ទីមួយ ទុកជាអនុស្សាវរីយ៍ជាដរាប ។ ព្រះបាទជយវរ្ម័នទី ២ កាលទ្រង់ធ្វើព្រះរាជសង្គ្រាមស្រង់ប្រទេសជាតិមាតុ-ភូមិ ឲ្យរួចអំពីឋានៈជាអាយ័ត្តជ្វាហើយ ទ្រង់ក៏បានបាត់ការកសាងតាមប្រវេណីនេះ គឺដំបូងទ្រង់សាងក្រុងថ្មី ១ ឲ្យឈ្មោះថា "ហរិហរាល័យ" (ដែលពាក្យសាមញ្ញ ហៅថា លលៃ) នៅក្នុងស្រុកស្ទឹងគម ខេត្តសៀមរាប ក្នុងបច្ចុប្បន្ន ហើយស្តេចចេញពីក្រុងឥន្ទ្របុរៈ ទៅគង់នៅក្រុងថ្មីនេះ ។ តពីនោះ ជាការៈទី ២ ទ្រង់បានសាងប្រាសាទថ្មី ១ ហៅថា "អមរេន្ទ្របុរៈ" (បន្ទាយឆ្មារ) នៅក្នុងស្រុកខេត្តបាត់ដំបង ហើយឆ្លាក់រូបភាពគង់ទ័ពរបស់ព្រះអង្គ ដែលធ្វើសង្គ្រាមជាមួយជ្វា មានជ័យជំនះ ទុកជាអនុស្សាវរីយ៍ តាំងជាប់ជាប្រវត្តិសាស្ត្ររបស់ជាតិឯង ។ តអំពីនោះ ជាការៈទី ៣ ទ្រង់បានសាងព្រះរាជធានីថ្មី ១ អន្លើទៀត នៅលើខ្នងភ្នំគូលេន ហៅថា "ក្រុងមហេន្ទ្របព៌ត" ហើយស្តេចចេញពីក្រុងហរិហរាល័យ ទៅគង់នៅក្រុងថ្មីនេះ ។ ស្ថានទីដែលពោលនេះ សឹងមានជាភស្តុតាងនៅដល់សព្វថ្ងៃនេះ ។ (នៅមានត)

# សុភាសិត ភាគទី ២

លោក ក៉យ-ប៊ុក ក្រមការ រៀបរៀង

(តមក)

## បកិណ្ណកវគ្គ (គ)

៥ – កុំលំទុនអង្គុយបក់ស្នា ធ្វើចិត្តហានក្លាសាងជាតិថ្កើង ទើបប្រទេសជាតិបានរុងរឿង ជាតិថ្កើងទ្រុះថ្កើងដល់សាសនា ។

៦ – មនុស្សក្រុចឆ្មារធុរសេចក្តីកាល ស្វែងអំពើពាលការទុច្ចរិត មនុស្សទឹកត្នោតតែងប្រព្រឹត្ត សុចរិតពិតពុំសង្កា ។ បុគ្គលនេះនោង ខូចដល់ចាស់ បុគ្គលស្វាយស្លុះអកុសលា ពីទារកក្មេងកាបតាមការ លុះដល់ជរាប្រែសម្អម ។

៧ – កុំត្រាប់កង់គេឯប្រចណ្ឌប្តី ត្រាប់មាន់ប្រាជ្ញស្តីការសច្ចៈ កុំត្រាប់កុកសប្រហែសជាប់ ត្រាប់កុកសាបច្នាក់អប្បមាទ ។ កុំឲ្យត្រាប់ត្មាតរកកូនលាមក ឲ្យត្រាប់បានសុខតាមច្បាប់ខ្មាត ត្រដេវរិបរក្យ ស៊ីតសង្អាត ប្រាជ្ញឆ្លាតប្រយ័ត្នមិនធ្វេសខ្លួន ។

៨ – បើកូនគេដូចខ្លាក់ក្អែកពីរ ខ្លាក់ម្ខាងពេញទំ បើកូនឯង បើប្រើកាត្មាប្រាកដស្តែង ដូចក្អែកក្ងីបែងចាំងរង្សី ។

៩ – ធុងទទេឮសូរសព្ទខ្លាំង សុនខសាំះព្រុសមិនដែលខាំ រុក្ខជាតិព្រឹក្សាផលាដាំ ផ្កាច្រើនចំណាំមិនសូវផ្លែ ។ ផ្គរសូរច្រើនដងមិនដែលភ្លៀង មនុស្សក្រៀសក្រៀងតាមសព្វបែប និយាយប្រាជ្ញប្រានអួតពូកែ តែបែរកក្ដីមកស្គាល់ល្ងិតល្ងង់ ។

១០ – កន្ធែបខែក្ដៅត្រូវភ្លៀងធំ សប្បាយស្រួលសមដូចបុប្ផា ត្រូវទឹកសន្សើមធ្លាក់បស្ដា សុខស្រួលកាយាគ្មានទុក្ខភ័យ ។ មនុស្សណាមានទុក្ខក្ដៅក្រហាយ បានដល់សប្បាយឈ្នះជោគជ័យ ភ្លេចនឹកទុក្ខព្រួយហេតុបច្ច័យ និស្ស័យជាតិមនុស្សគិតតែសុខ ។

១១ – កន្ធែបនៅក្នុងអន្លង់ទឹក ស្មានមេឃតូចនឹកប៉ុនគ្របត្នាំង បុគ្គលល្ងិតល្ងង់អវិជ្ជាបាំង តែងចាត់ខ្លួនតាំងប្រសើរឯក ។

១២ – ទុក្ខខ្សោយជាងចិត្ត សត្វខ្សោយកម្មពិត លោកខ្សោយជាងធម៌ ជាតិខ្សោយសាសនា លាភខ្សោយល្អ អាត្មាខ្សោយគរជនសក្រឃើញ ។

១៣ – គ្រីស្តូហ្វូលមប៍ជាអ្នកប្រាជ្ញ អេស្ប៉ាញអាចរកទ្វីបអាមេរិកបានឃើញតាមប្រាជ្ញា បេះស្ងួនមើលការបានសម្រេច ។ ដល់ត្រឡប់វិញមានពួកបច្ចា ពោលពាក្យនិន្ទាស្តីបន្ទាប ថាការទៅរកតំណែលត្រែច អាមេរិកស្រេចជាងាយស្រួល ។ គ្រីស្តូហ្វូលមប៍យកពងមាន់ដាក់លើតុកាន់ពាក្យបបួល ប្រកាសប្រាប់បុគ្គលឲ្យទទួល ផ្តួលដាក់

បញ្ញាលើតុបាន ។ មិនមានអ្នកណាប៉ុនប្រសប់ ធ្វើមិនកើតគ្រប់ នាគូមិស្ថាន គ្រឹស្តហូប្រឹទុបាយបត្តភាហាន គោះពន់មានបានបញ្ញា តាម ។ បុគ្គលតច្ចាចាធ្វើបាន ប្រាកដគោះបានៈប៉មិនបាម អ្នក ប្រាជ្ញថាការកេតិតក្លាម ស្រួលងាយដ៏តជាមមិនយល់ងាន ។

"ការងាយខាងល្មើ លំបាកតិតអង្គ ខាងពួកបណ្ឌិត ដែនទីសម្រាប់ ពួកវិះពិនិត្យ មេទ័ពស្គាល់ចិត្ត គំនិតសត្រូវ" ។

១៤ – ទ្រូបជាគ្រូបច្ចុប្បន្ន បង្កើនគាត្រាស្រឡាញ់ជាតិ អាស៊ីជាគ្រូសង្ខាត ប្រដៅទុកទៅអនាគត ។

១៥ – មនុស្សត្រូវពឹងមនុស្ស ក្រោមស្មោះ ជន្ទន់ពឹងទឹង មនុស្ស ត្រូវពឹងសត្វ ទាបយកខ្ពស់ពឹង ធំផ្អែកតូចសឹង បង្កោលរង់រឿង ៗ បណ្ឌិត ធម្មា បុរេពឹងពាលា ត្រឡាបពឹងទ្រើង ជាតិដែលរស សម្ពឹង គ្រឿង មហាកដកុំប្រើង ដោយពលទាហាន ។

១៦ – ឃើញសុំបកថាខ្ញុំមរក្ខា យល់ពួកបច្ចាថាជាមិត្រ ពាល ជនប្រទៀបថាបណ្ឌិត ប្រម្យលាមកពិតថាបុប្ផា ។

១៧ – មនុស្សមានភ្នែកល្អិត មានទ្រព្យច្រើនពិត ហៅក្រ ពេកពន់ បេះមិនប្រតិបត្តិ ហៅល្អលើសលន់ មានវិទ្យាគុណ ហៅ មានប្រាកដ ។

១៨ – កុំយកមាន់ទៅផ្ញើនឹងស្ទាំង កុំយករមាំងទៅផ្ញើនឹងខ្លា ឯជាតិភេកុំផ្ញើមច្ឆា កុំផ្ញើមនុស្សា ប្រាក់មាសពេជ្រ ។

១៩ – ធ្វើស្រែយកស្រូវ បើកៀបអំពៅ គេយកស្ករជាតិ បុគ្គលជួយយើង ប្រាជ្ញាសង្វាត កម្រៃតាមខាត មិនមែនទទេ ។

២០ – អ្នកធ្វើជំនួញ ចេញសំពៅជួញ ខាតក្បាលចំណេញ មិនដែលហៅខាត អ្នកចំបាំងចេញ ចូលទៅប្រដេញ ព្រោះឃើញជោគជ័យ ។

២១ – រុក្ខាខ្ពស់ធំ វាយោប្រជុំ បោកបក់ខ្លាំងក្លា រលំលានឮ សត្វព្រៃព្រឹក្សា ស្នូរសព្ទលោកា ជាងស្មៅដើងក្រាស់ ។

## ឥត្ថីវគ្គ

១ – បើការស្លាប់រស់កុំប្រាប់ស្ត្រី បើបានជាខ្ញី ៗ ប្រាក់ទិញ ការស្ងាត់កំបាំងកុំបញ្ចេញ បើបានជាវេញខ្សែមូលមួយ ។

២ – ស្រីស្អាតត្រង់ភក្ត្រ សំពត់ល្អជាក់ ចំពោះជរជាយ អ្នកមានបុណ្យស័ក្តិ គ្រឿងយសធោមធាយ ជាតិឯកកដផ្សាយ ល្អផុតលោកា ។

៣ – មនុស្សមិនស្គាល់មនុស្ស កុំយកចំពោះ ធ្វើការឧត្តម ស្រីពុំស្គាល់ស្រី កុំឲ្យសេពសម ភរិយាជាធំ អភ័ព្វវិនាស ។

៤ – រុក្ខាផ្លាស់ពណ៌ពេលផ្កាផ្លែ នារីប្រែវណ្ណាដល់យុវតី ផ្លាស់ធាតុមនុស្សសត្វសព្វបក្សី ចេញចូលប្រស័យគ្រប់វេលា ។

៥ – ស៊ូយកស្រីផ្កាមាសជាភរិយា មិនឲ្យធ្វើពេស្យាប្រពន្ធខ្លួន ស្រីរដ្ឋប្រសើរក្នុងទ្វីបបួន មិនស្មើលោកស្រីចាំង-កៃ-ចិក ៗ ប៉ុនជួយស្វាមីតាំងសែអាន ឧបាយកល្យាណកលកិច្ចទឹក មានប្រាជ្ញាចូលខាងអាមេរិក វរស្រីនាំដឹកជាតិចិនថ្កើង ៗ

៦ – ឫទ្ធិអំណាចស្រេចមច្ចុរាជ កម្លាំងអង្គអាចស្រេចស្រមោប មហាសុខទិញានអស់ពូជ មរនោស្រួចមុតជាប់ស្ត្រី ៗ

៧ – ធ្មេញតែងខាំជ័ហ្កអណ្តាត បានការជាខ្នាតតែងរណ្តំគ្នា កស្តាទេតីនៅរួមគ្រឹះហា គង់ទាស់គាគ្នាឈ្លោះមិនខាន ៗ

៨ – កុំយកអង្ករស្រូវធ្វើនំមាន់ កុំយកផ្កាច័ន្ទន៍ធ្វើនំស្រី កុំធ្វើជាងឈើដែកស្វានខៃ កុំធ្វើត្រយ៉លក្ខណ៍ខឹងពួកពាល ៗ

៩ – តរុណានៅជិតតរុណី គ្រប់នៅជិតរុក្ខាបេក ហត្ថីអំពៅចូលបោចសែក ស្រមោចស្ករវប្ងកព់តម្រែង ៗ

១០ – ផ្សារកំពង់ទឹកមិនដែលស្ងាត់ ខាងការប្រាសព្រាត់ស្រេចសង្ខារ ជនទាបបំពើតដល់មេឃា ស្រីមានកស្តាទើបសោភ័ណ ៗ

១១ – ស្ត្រីល្អមានខ្មាស ផល់ចិត្តវិបល្លាស គេក្តិឈ្មោះអាស្រូវ ចេញមុខបាត់អៀន ពេស្យាពាលផ្លូវ បុកណាប្រដៅ ឥត្ថីកិរិយា ៗ

បណ្ឌិតខ្មាសបាប សេពគប់ពាលភាព សង្រ្គមអាត្មា ដល់ពួកសត្វសួរ
គតគូមិលោកា អាសោចកាយា ធ្វើបាបក្លាហាន ។

១២ – កុំកាន់ធម៌ស្រី កុំត្រាប់ប្រាជ្ញស្ដី ស្វាត្រូវពាំយោ ទុកដិះ
ឃ្លេងឃ្លោង ចូលទឹកពេញពោរ កុំឲ្យឡើងដោរ ដោយសារពាក្យស្រី ។

១៣ – នាងវិសាខា កូនកតលោកា ជាស្ត្រីឧត្ដម បុប្ផាក្រអូប
លោកធាតុស្ងួតព្រហ្ម បញ្ចពិធល្អសម នារីវិសេស ។

១៤ – ស្រឡាញ់ណាស់ប្រែស្អប់ បុត្រល្អសំណប់ ថ្នមហួស
ខូចខុស ស្រឡាញ់ភរិយា ប្រែប័ណ្ឌសាយសុស ស្រីដែលស្អប់ប្រុស
ច្រើនធាប់បានប្ដី ។

១៥ – ស្ត្រីខំតាក់តែងខ្លួនប្រាណស្អាត ប្រែស់មៀវតាមខ្នាតវឹក
អប់ឈ្ងុយ សំពត់ល្អិតក្លឹរសក់ផ្គង់ស្អុយ មារយាទរុយពេស្យាអាត្មាបង់ ។

(ខ) ស្ត្រីតាក់តែងខ្លួន លាបម្សៅក្រមួន ទឹកអប់គន្ធ
ស្លៀកពាក់ស្អាតសម ពន់ក្ដន់មិនស មេឃស្អាប់ពុំល្អ បណ្ឌិតស្គាល់
ជាក់ ។

១៦ – ធ្វើការជាមួយប្រុសពាលព្រួយល្មម លំបាកណាស់ព្រម
ស្រីពាលា ធ្វើការគ្មានរបៀបរងខ្លោចផ្សា ពួកសប្បុរិសារួមស្រួល
ងាយ ។

# បណ្តាំមាតា

## ឃុនសិរីមេធី ស្រី-អ៊ូ រួបរួម

(តមក ចប់)

---

ឈានជើងញ៉ាំញ៉ើញាប់រន្ទួញ  លលេញងើកងោកដើរងើល
រប៉ុលរប៉ូចដូចគេផ្អើល  ធ្វើព្រើលជាក្អកឲ្យប្រុសដឹង ។
គ្រហែមណោះណោះប្រុសមិនបែរ  ធ្វើជាក្អួញក្អែរស្តីដូចខឹង
តតក្តេតតក្ខាសក្តាសមិនដឹង  គានគឹងស្ទើរតែទឹងជាប់ខ្យល់ ។
ខ្លួននាងក្រមុំកុំធ្វើផ្តាស  ភ្ញាក់ឡើងបំភាសអស់កិច្ចកល់
គេក្តេក្ខាសក្នុងប្រាណមិនមានសល់  ហួសដល់លោកសង្ឃនៅឯវត្ត ។
រីរឿងជ្រលួសដួសរកចា  ចិត្តស្ម័គ្រចង់ថាថែមប្រាកដ
ពុំត្រង់ស្លុងស្លូតរបូតមាត់  ពិតជាបំភ្លាត់តាមសញ្ញា ។
ដូច្នោះបំពោះពិតប្រាកដ  មិនជឿឲ្យស្បថចុះពល់គ្នា
ជាក់ជាក្នុងចិត្តគិតចង់ថា  នរណាមិនដឹងដំណើរនោះ ។
នេះឯងខាតលក្ខណ៍ជាក់ជាជន  ជួរពោកពាន់ពិតបំពោះ
ចង្រៃក្រពោកពុំរគោះ  ហេតុព្រោះដ្បិតខ្លួនមិនតាមច្បាប់ ។
ដេកយប់ទាស់ទ្វារបង្អួច  សឹកទាស់ទាល់រួចឲ្យសព្វគ្រប់
ថែទាំរៀបចំរបស់ទ្រព្យ  រិះរាប់ឲ្យដឹងជាដើមចុង ។
មើលសព្វភ្លើងផ្សែងក្រែងព្យុះខ្យល់  បក់បោកមកដល់ក្ទឹប៉ុង

រង្គុំកាត់ខុសប្រុះព្រានកុង / ដើងគ្រាន់ក្រែងផុងលោះឆេះផ្លុះ ។
បើសួនបណ្ដូលចូលទៅហើយ / ហុកតួកខ្វល់ខ្វីយមើលឲ្យជ្រះ
ថៃឲ្យស្អាតស្អំសំនាងប្រុះ / ដេកទៅរហ័សឆាប់ភ្ញាក់ឡើង ។
លុបមុខខ្នុរមាត់មាសស៊ីស្លា / រួចហើយម្នីម្នាកុំកន្ទ្រើង
ក្រោកឡើងទន្ទ្រំផ្លុះនឹងដើង / បបើងបរបេញមកក្រៅហាន ។
រំសាយទាំងសក់អាក្រក់ក្រៃ / ពេញហៅចង្រៃពន់ប្រមាណ
ខាតអស់នរលក្ខណ៍សក្តិយសប្រាណ / កល្យាណកុំធ្វើដូច្នោះណា ។
កុំនាងលីលាទៅលេងឆ្ងាយ / កំបាំងពីម្ដាយទៅមិនថា
ស្រែកច្រៀងរំពងពុំនឹកនា / ក្រែងគេនិន្ទាទៅផ្ដេសផ្ដាស ។
ប្រុសប្រាណបានឃើញដូច្នោះឯង / មិនលែងឡកឡើយណាកូនមាស
ម្ដាយឃើញម្ដាយយល់តែអំពាស / កាប់ខ្នាសមេបាមកប្រៀនហើយ ។
កុំនាងដាលដោយប្រុសល្អងលោម / រួមរសរូបឆោមជាតិជាត្រើយ
តែឆោតគាមរពុំជាឡើយ / កូនអើយប្រយ័ត្នកុំឲ្យធ្លាយ ។
បើឃើញកំឡោះដោះដៃបេញ / កុំនៅលលេញក្រែងក្រក្រោយ
កុំឃើញតែប្រុសចុះចង់ដោយ / ឡកលយឡេបឡប់ប្រែបព្រមភ្លឹង ។
ប្រឡែងប្រឡកល្ងកបំបម / ប្រឡោមប្លាក់ថ្នមបោសព្រលឹង
មិនមានក្រែងចិត្តឥតកំដឹង / រំពឹងឲ្យជ្រៅទៅក្រោយមុខ ។
តែទ្រាន់ប្រុងឡើងល្អចំណាប់ / ធ្វើការកាន់កាប់ចុះបានសុខ

ធ្កាព្រៃកនដីធ្វើស្រែស្រុក ទៀងទុកកេរ្តិ៍ក្រោយឲ្យកូនចៅ ៗ
ប្រុសខូចមិនដូចឯងស្រីទេ ហេតុនោះកុំមេជឿស្នុងសៅ
ធ្វើឆោតលលោតដោយគេទៅ ពាលពៅពុំត្រូវតាមពាក្យម្ដាយ ៗ
នាងចំប្រព្រឹត្តគិតប្រយ័ត្ន កុំឲ្យភ្លេចភ្លាត់ពាក្យបរិយាយ
ចូរចាំឲ្យម៉ាំណាកូនម្ដាយ គិតកាយកុំធ្វេសចូរគិតគន់ ៗ
ធម្មតាយកគ្នាចិត្តនឹងចិត្ត ពុំដែលថេរបិតដល់អស់ជន្ម
ច្រើនតែលែងចោលនៅពព្រាន់ ពិបាកចិត្តលន់លើសគេឯង ៗ
ហេតុព្រោះថ្មស់ខ្លោយដោយពាក្យព្រាង បញ្ឆោតឲ្យនាងលុះការល្បែង
ពក្កុតមុសាថាមិនលែង ធ្វើក្លែងស្បថស្បែតែមាត់ក្រៅ ៗ
គឺមោះក្នុងពោះមិនមែនសោះ ធម្មតាកំឡោះមិនដែលខ្លៅ
ប្រាជ្ញាកុងកាប់តាប់សំដៅ មិនដឹងស្ដាប់ទៅចូលចិត្តដោក ៗ
ទាល់តែធុកប្រាណបានដៃព រួមរសរូបាមិនអធ្យាក
មិនមានអាណិតគិតយល់យោគ ដល់កើតស្នាក់ស្នោកតាំងដាល់តប់ ៗ
ក៏ប្រែក្រឡះលែងព្រងើយ ធ្វើជាគោះតើយពិតពុំកប់
មិនមានលើកលែងប្រែជាស្អប់ ត្រឡប់ធ្វើជាមិនដឹងខ្លួន ៗ
ឯងនៅកំព្រាជាមេម៉ាយ សង្ឃឹមសហាយគេបះពួន
បង់កេរ្តិ៍ខូចឈ្មោះខុសក្រៅក្បួន មាសស្ងួនកើតកូនអត់ឧសអាំង ៗ
លំបិនលំបាកទ្រូងស្មើរបែក សម្រក់ទឹកភ្នែកមុខក្រៀមក្ដាំង

ព្រោះតែថ្ងួស់ផ្កាយដោយមោហ៍ចាំង ស្មោកគាំងគំនិតគិតទញ់គុះ ៗ

យ៉ាងនេះពុំគាប់ស្នាប់មិនខាន កុំធ្វើដូចបុាននិយាយខុះ
ម្ដេចៗខំទ្រាំអត់សិនចុះ កុំធ្វើឲ្យលុះខុសខ្ញុំប្រាណ ៗ
បើជាទោះបីល្អអាក្រក់ គំរក់គំរក់ក៏គង់មាន
ប្រុសឈ្មោលចូលស្ដីមិនដែលខាន ប្រុងប្រាណកាន់កេរ្តិ៍តាមច្បាប់ស្រី ៗ
ហៃកូនសំឡាញ់ពេញចិត្តម៉ែ នាងនែបើនាងទៅមានប្ដី
កុំខឹងក្រេវក្រោធឥតមេត្រី ប្ញូស្រីស្រស់ស្រួលទទួលទៅ ៗ
បើប្ដីខេវខឹងសំឡឹងមុខ នាងខំអត់ទុកឲ្យស្ងៀមនៅ
កុំឆ្លើយតបតប៉ោះប៉ោកទៅ ស្រីពៅខាំមាត់សង្កត់ចិត្ត ៗ
កុំខឹងប៉ោះប៉ោកគំហកតប ឲ្យប្ដីខ្ចាបខ្ជួបមិនមានគិត
ខ្លួនឯងជាស្រីស្រាលគំនិត ពេកពិតពុំដឹងខុសត្រូវអ្វី ៗ
ស្ងួនម្ដាយនាងធ្ងន់តម្រង់ចិត្ត ផ្ចិតផ្ចង់គំនិតប្រតិបត្តិប្ដី
នាងបៀកស្វាមីបុរី កុំបីធ្វេសប្រហែសខ្លួន ៗ
យប់ព្រឹកព្រលប់ទឹកប្រៀបប៉ុង ប្រដាប់ប្រៀបប្រុងមើលថែថ្នួន
រៀបរួចសិតទឹកមកមែនមួន ហើយស្ងួនលើកបាយជាបន្ទាប់ ៗ
បៀកស្វាបុរីដាក់ជើងពាន ភ្លើងថៃ្ងស្រោកមានគ្រប់ប្រដាប់
យកមកឲ្យសព្វគ្រប់ស្រេចស្រាប់ កុំឲ្យប្ដីច្រាប់ញយៗដង ៗ
លើកបាយដល់មករកហៅប្ដី សំណេះមេត្រីកុំបីធ្ងន់

អញ្ជើញពិសាណាអ្នកបង　ស្ងួនគ្រងស្រពាយទៅកាន់ប្ដី ។
ប្ដីមកដល់ប៉ោកអន្ទុយប៉ុក　នាងទៅពីមុខគាល់ស្វាមី
មើលបេះដូងផ្អែងក្រែងប្ដីសិ　នឹងអស់អ៊ីៗ ត្រូវជួសជាក់ ។
ថែមទៀតជាថ្មីកុំបីខ្ចិល　ប្ដីទាញរម្កិលថាសចេញជាក់
នាងហុចពានស្លាថាហៃអ្នក　វរលក្ខណ៍ផ្ដេះប្ដោះណាពាលទៅ ។
ប្ដីហូបរួចពលស់សល់ប៉ុន្មាន　សមកូនកល្យាណនាងលើកទៅ
រៀបរកស៊ីចុកចែកកូនចៅ　ទើបហៅគោតខ្ញាបស្វាមីភក្តិ ។
ថាបើប្ដីប្រាណមានមេត្តា　ឲ្យញ៉ាំផងគ្នាស្ងួនវរលក្ខណ៍
ឲ្យប្ដីហូបបានបីម៉ាត់ជាក់　ស្រេចហើយទើបអ្នកនាងញ៉ាំក្រោយ ។
អន្ទុយបត់ដើងឲ្យត្រឹមត្រង់　រៀបអន្ទឲ្យគួរកុំបីឆ្ងោយ
មានស្បៃពាតបានាងកុំឲ្យ　ខាតខុសតាមដោយច្បាប់តម្រា ។
ចំពូកមួយទៀតរដំណេក　បើនាងចូលដេកឲ្យខុសព្យាហ៍
ហោសពូកខ្ទើយខ្នល់ហើយនិទ្រា　ពុំងាកុំគេងត្រឹមនឹងប្ដី ។
ត្រូវប្ដីចូលដេកមុនប្រពន្ធ　ហើយសិមស្រីតនទូបពិសី
ចូលទៅនិទ្រាជាក្រោយខ្ចី　ទើបត្រូវតគបីមានខុសច្បាប់ ។
ដេកកុំឲ្យលក់លុះព្រឹកព្រាង　ចរៃផ្ទៃដល់នាងពិតពុំគាប់
ក្រោកឡើងមុនប្ដីស្រីប្រញាប់　ផ្គត់ផ្គាប់សិតទឹកទុកឲ្យប្ដី ។
រៀបស្លាម្លូថ្នាំប្រចាំនៅ　កន្ទាបណាទៅកែវពិសី

ដល់ថ្ងៃរៀនរះពេញតិថី ហើយស្រីតណ្ហាំបាយទឹកទៅ ។
ប្រយ័ត្នក្រែងជួនជាប្ដីសី ចេញទៅពនដីប្ដុំពាយផ្ដៅ
កាប់ខុសបុស្សអ្វីណាពៅ ការក្រៅដទៃក្ដីណានួន ។
កុំស្ដីដើមប្ដីត្រខ្លួរខ្លារ ដូចគេដេកផ្ទារស្ដោះលើខ្លួន
ខូចជាយ៉ាងណារក្សាស្ងួន បំពួនបំពាក់លាក់ទៅជា ។
បើប្ដីមានយសខ្ពស់បុណ្យសក្ដិ មានមនុស្សពឹងពាក់បុណ្យវាស្នា
នាងកុំវាយដំបន្ទុំវា នោះនឹងរួញរាពុំលែងឡើយ ។
ថាបើមានខ្ញុំកំដរផង នាងយកចិត្តបង់កុំគោះតើយ
កុំវាយកុំដេវដាំនោះឡើយ ពៅអើយនាងស្ដាប់ម្ដាយឧបមា ។
បើនាងមានចិត្តគិតយោគយល់ ដូចកល់ទឹកជ្រៅត្រជាក់ថ្លា
អស់ទាំងនាគាសត្វមច្ឆា ត្រីច្នាពឹងពាក់សំណាក់នៅ ។
ថាបើទឹកក្ដៅនៅពុំបាន នឹងគិតប្រែប្រាណបៀសចេញទៅ
នៅពុំបានសោះព្រោះទឹកក្ដៅ គេហៅគង្គាអាប់គតបទ ។
ទឹកឧបមាដូចកូនស្ងួន ពាក្យកខ្វីមខ្លួនកែវកំសត់
ឯមច្ឆានោះប្រាកដ សន្តោះទុកជាដូចមនុស្សផង ។
ដែលខ្សត់ពីបាកយ៉ាកជន្ទាក់ វត់មកពឹងពាក់លើខ្លួនល្អង
បើនាងមេត្តាវាជាម្ដង ផ្គួងដូចជាទឹកត្រជាក់ ។
ថាបើនាងធ្វើកញ្ជាក់ពេក មិនមានអគ្យាគវាយប្រែជាក់

យប់ព្រឹកសន្ធឹកឥតមានអាក់ រលាក់រលើរង្វើពុំគិត ។
បើផ្ញើជួបឆ្មោះពលែងនៅ រត់ចេញចោលទៅបង់គំនិត
អស់ពីអន្លក់ពុំស្បិត ព្រោះដៀតនាងធ្វើក្រែលែងច្បាប់ ។
នេះឯងដូចជាគន្លាក្ដៅ ត្រីពឹងពុំនៅភ័យក្រែងស្លាប់
ហេតុនោះកូនសន្ធួនទាំងស្លាប់ ម្ដាយប្រាប់ប្រដៅដោយមាត្រា ។
កុំឃើញប្រុសល្អបរចោលប្ដី ដើមនោះឥតបីបើទឹកទា
ស្រឡាញ់ថ្នាំងថ្នាប់ម្ទង ចិត្តពុំមិនគិតក្ដីក្ដៅសន្ធួន ។
លុះដល់ខ្លួនប្រាណបានទោរ ល្អកណាប្ដីដឹងជានឹមខ្លួន
ប្រព្រឹត្តផិតក្ដាសលាក់បំពួន ដាប់ផ្ទួនជិតដោយសុហាយស្ទន់ ។
ប្ដីដឹងគេកាយប្រែធាក់ផង គេចាប់គេចងធ្វើទុក្ខគន់
គេលក់គេលែងឯងអៀនអន់ ទទ្រន់ទ្រកអ្វីគ្មាន ។
ពីបាកដល់ក្ស័យនៃជីពជន្ម នៅរងទុក្ខធ្ងន់ឥតស្រាកស្រាន្ត
ស៊ីខុះឈាមសាច់សាចម៌ខ្លួនប្រាណ ពុំបានបាយទឹកដល់គិបត្ថូប ។
យមបាលអ្នកចាប់បានកាយា ឲ្យឡើងរកាបន្ទាស្រួច
មុតអស់ខ្លួនប្រាណប្រែពុំរួច ស្រែកយំគ្រលួចព្រួពាង ។
គ្មានក្អែកប្រញឹកបឹកស៊ីពាស សាច់ដាច់ដាប់ដាសចំពុះផង
ឈាមហូរស្រស្រាក់ធ្លាក់ពាយរង ទុក្ខធ្ងន់កន្ទង់ឈឺខ្លោចផ្សា ។

ទោះទាំងថ្ងៃយប់គ្រប់ពេលពិត ពុំមានស្បើយស្បិតដល់តិចណា
គ្មានទាំងសំពត់វណ្ណអាត្មា កាយាទទេទំនេរនៅ ។
ស្លាប់កើតមួយថ្ងៃមួយរយដង ពីបាកគន្លងរងទុក្ខជ្រៅ
ទោះអស់បងប្អូនកូនញាតិផៅ ធ្វើបុណ្យជូនទៅពុំរដោះ ។
ព្រះពុទ្ធត្រាស់ជាអម្បាលខ្លាច ប្រោសប្រាណពុំដាច់ពុំរួចសោះ
ពីត្រង់ស្រីចោរផិតប្តីនោះ រងគ្រោះកំណត់ប្រាំរយជាតិ ។
គ្រាន់តែរដោះពីទីជ្រៅ មករងទុក្ខនៅពិតពុំឃ្លាត
កើតជាប្រេតប្រាណព្រោះប្រមាទ- ផិតប្តីជាអាទិ៍ឲ្យវេទនា ។
ហេតុនោះឯងមិញសំឡាញ់ម្តាយ ទំផិតធ្ងន់កាយភល់ទាក់
កុំឲ្យខូចកេរ្តិ៍ណាសួនក្លូ គ្រប់ពេលវេលាតទៅទៀត ។
ប្រយ័ត្នប្រាណប្រុងអង្គកាយកល់ គិតគន់យោបល់ឲ្យបង្អៀត
កុំឃើញតែងាយហើយល្មួចល្មៀត សិកសៀតណែះណោះណា
មាសមិត្រ ។

កាលដើមខ្លួនម្តាយនៅក្រមុំ ប្រុសធងចោមជុំម្តាយមិនស្បិត
ឲ្យពាក្យសំដីស្តីមកស្និទ្ធ ម្តាយពុំលង់ចិត្តឆោតដោយគេ ។
តែពុទ្ធរណ៍ថាណោះណោះ ម្តាយចៀសចេញស្មោះមិនព្រាលព្រៃ
មិនផិតមិនស្និទ្ធស្គាលទៀតទេ ឆាកវេប្រែប្រាណដើរចេញទៅ ។

ម្ដាយរក្សាប្រាណដល់មានប្ដី មិនមានមោះអ៊ីទេណាពៅ
គ្មានប្រុសណាមួយមកឆានៅ ប្រាជ្ញខ្លៅសរសើរសឹងគ្រប់មាត់ ។
ឥឡូវនេះម្ដាយចាស់ម៉េះហើយ ស្រីថ្លៃម្ដាយអើយចាំកុំភ្លាត់
ធ្វើតាមពាក្យម្ដាយឲ្យប្រាកដ តាមដោយបូរបទកុំឲ្យឃ្លាត ។
ទោះបីស្រីណាបើបានស្ដាប់ ធ្វើតាមបង្គាប់នេះដាច់ខាត
ស្រីនោះនឹងបានស្ថានសួគ៌ស្អាត ប្រាសាទប្រសើរសឹងសុវណ្ណ ។
ប្រកបស្រីស្នំក្រមការផង មាសប្រាក់កែវកងច្រើនត្រៀបត្រា
សឹងសុខឥតទុក្ខកងអាត្មា ទាល់រួចដល់មហានិព្វានហោង ។

ចប់

---

# ស័ព្ទបារាំងប្រែជាខ្មែរ

របស់

## គណៈកម្មការវប្បធម៌ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(តមក)

Compte courant = គណនីចរន្ត

Capital social = ដើមទុនក្រុមហ៊ុន

Courant = ចរន្ត

Créances = ប្រាក់គេជំពាក់

Concessionnaire de mine = អ្នកទទួលសម្បទានអណ្តូងរ៉ែ

Capitalisme = មូលធននិយម

Capitaliste = មូលធនិក

Créancier = ម្ចាស់បំណុល

Dette = បំណុល

Colon partiaire = អ្នកទទួលប្រវាស់ដី

(Le Mardi 17-8-48

Merveilleux = អស្ចារ្យ

Merveille = អច្ឆរិយវត្ថុ

Une grande âme = មហាត្មា

Humanité = មនុស្សធម៌, មនុស្សជាតិ

Emotion = ការរំជួលចិត្ត

Epreuve = វិញ្ញាសា

Vérité = សច្ចៈ សត្យ

Merveilleux = អច្ឆរិយគតិ

Miracle = បាដិហារ, អព្ភុតហេតុ

S'émouvoir = រំជួលចិត្ត

(Vendredi 20 8-48)

Société Franco-Khmère de Navigation = ក្រុមហ៊ុននាវាចរ-
បារាំង-ខ្មែរ

Féminisme = នារីនិយម

Sociologie = សង្គមវិជ្ជា

Club = ក្លឹប (សមាសាននយោបាយ, កីឡាមណ្ឌល, មិត្តសមាគម)

Extrémiste = អច្ចន្តិកជន, អច្ចន្តិកៈ

Modéré = មជ្ឈត្តិកៈ (ស. មជ្ឈត្តិកា)

Impôts sur les revenues = ពន្ធលើផលទុន

Impôt sur les bénéfices = ពន្ធលើចំណេញ

Impôt sur les traitements de salaires = ពន្ធលើបៀវត្សរ៍

Impôt général sur le revenu = ពន្ធទូទៅលើផលទុន

Le Mardi 24-8-48)

Cession d'élément d'actif = អនុប្បទានវត្ថុធាតុសកម្ម

Caisse sociale = ហិបប្រាក់ក្រុមហ៊ុន

Capitaux mobiliers = មូលធនសង្ហារិម

Capitaux engagés = មូលធនជាប់ប្រើ, ដើមទុនជាប់ប្រើ

Elément = ធាតុ, វត្ថុធាតុ

Capitaux disponibles = មូលធនទំនេរ

Capital mobilisé = មូលធនកប់

Capital investi = មូលធនប្រកបការ

Dégrèvement... ការលោះលា
- décharge = ការដោះបន្ទុក
- réduction = ការបន្ថយ
- remise = ការបង្វិលឲ្យ
- modération = ការសម្រាល

Evaluer = វៃតម្លៃ

(Vendredi 27-8-49)

Présidente = អធិបតីនី, ប្រធានិកា

Echelon = លំដាប់

Echelonner = តាមលំដាប់

Moins-value = តម្លៃថយ

Plus-value = តម្លៃលើស

Mensualité = អនុមាស

Négociant = មហាពាណិជ

Commerçant = ពាណិជ, អ្នកជំនួញ

Marchand = ឈ្មួញ

Vendeur = អ្នកលក់

Réforme = ការកែទម្រង់

Bilan = តុល្យាការ

Révaluation = ការរើលៃតម្លៃ

(Le Mardi 31-8-48)

Membre bienfaiteur = សមាជិកឧបការី (ស) - ឧបការិនី

– d'honneur = – កិត្តិយស

— donnateur = – ជនក (ស) ជនិកា–

– militant = – យុទ្ធិក (ស) យុទ្ធិកា

— actif = – សកម្មិកៈ (ស) សកម្មិកា

— adhérant = – សទិទ្ធ, (ស) សទិទ្ធិកា

– sympatisant = – សមានចិត្ត–

Savoir-vivre = សុជីវធម៌

Courtoisie = បោរីភាព

Affabilité = មនុញ្ញភាព (គួរស្រឡាញ់)

Aimabilité = ប្រិយភាព

Education = ការអប់រំ,ការប្រៀនប្រដៅ,ការសិក្សា

Tacite reconduction = ការបន្តអាយុដោយតុណ្ហីភាព

Valeur intrinsèque = តម្លៃសជ្ឈត្តិក:

— résiduelle = តម្លៃភាគ

— en porte feuille = តម្លៃក្នុងសំពៀត

Porte feuille = សំពៀត

Valeur extrinsèque = តម្លៃពាហិរក:

Licence de distillateur = អាជ្ញាប័ណ្ណអ្នកបិទស្រា

Liquoriste = អ្នកលក់ទឹកស្រវឹង

Fabriquant = អ្នកធ្វើ

Dénaturateur = អ្នកបំប្លែងធម្មជាតិ

(Vendredi 10-9-49)

Titre d'identité de 194 . . N° . . . demeurant à . . . est antorisé à exploiter à . . recette de. . . un établissement pour. . .

suivant décision N° . . . = អត្តសញ្ញាណប័ណ្ណ (ប័ណ្ណ) សំគាល់ខ្លួន

គ. ស. ១៩៤ – លេខ . . . នៅនា . . .

បានទទួលអនុញ្ញាតឲ្យបិទស្រានៅនា...

ផ្នែក . . . ក្នុងគ្រឹះស្ថានមួយៈដើម្បី . . .

តាមលិខិតសម្រេចលេខ . . . . . . ។

Il devra se conformer à tous les règlements sur la matière =

អ្នកទទួលអនុញ្ញាត ត្រូវប្រព្រឹត្តតាមបទបញ្ជាទាំងពួងក្នុងរឿងនេះ ។

Cette licence devra être affichée dans un endroit apparent de

l'établissement = អាជ្ញាប័ណ្ណនេះត្រូវបិទទុកនៅកន្លែងណាមួយ ដែល

គេមើលឃើញដោយងាយក្នុងគ្រឹះស្ថាន ។

Licence gratuite délivré ce jour par nous, receveur soussigné à M . . .

A. . . le . . .

Le Receveur

នេះជាអាជ្ញាប័ណ្ណ ដែលយើងនាយផ្នែកបានចុះហត្ថលេខាខាងក្រោមនេះ

ឲ្យក្នុងថ្ងៃនេះ ដោយឥតយកថ្លៃចេញឲ្យដល់ . . . .

— — — នា . . . នៅថ្ងៃ . . .

នាយផ្នែក

Timbre de l'entrepôt = នាយផ្នែក . . .

Licence de débitant en gros pour la vente exclusive des alcools indigènes

Est autorisé ouvrir à . . . un établissement pour la vente en gros des alcools indigènes exclusivement = បណ្ណសម្រាប់អ្នកលក់ដុំ ចំពោះតែស្រាអាយបានទទួលអនុញ្ញាតឲ្យតាំងនា . . . នៅគ្រឹះស្ថានមួយ ដើម្បីលក់ដុំបានតែស្រាអាយ ។

Il devra se conformer . . . et notamment aux dispositions du titre 8 de l'arrêté du 18 octobre 1921 = មានបទបញ្ញត្តិក្នុងជំពូក ៨ នៃអារេតេ ចុះថ្ងៃ ១៨ តុលា គ. ស. ១៩២១ ជាដើម ។

La présente licence valable pour l'année 19 = អាជ្ញាប័ណ្ណនេះប្រើបានក្នុងឆ្នាំ ១៩ . . .

Perçu la somme . . . piastres = បានទទួលប្រាក់ចំនួន . . . រៀល

Pour droit de licence = សម្រាប់ជាតម្លៃអាជ្ញាប័ណ្ណ

Quittance N° . . . de ce jour = បង្កាន់ដៃលេខ . . ចុះថ្ងៃនេះ

Le Receveur provincial

នាយផ្នែកប្រចាំខែត្រ

Les marchands colporteurs sont toujours tenus de présenter la licence à toute réquisition = អ្នករែកលក់ ត្រូវបង្ហាញអាជ្ញាប័ណ្ណនេះជាដរាប បើមានអ្នកកាន់ការមកតាមមើល ។

Distillateur = អ្នកបិទស្រា (មានត)

## ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា

៦

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ប្រៀបរៀង

(តមក ចប់)

---

ការន័តតាំងមូល នៅគ្រានោះ អាណាចក្រវិជយនគរ មានអំណាចគ្រប់គ្រងប្រជាជនដល់ ៣ ចំពូក គឺពួកម៉ស្លូ, ពួកតេលុគុ, នឹងពួកទមិឡ ។ វិជយនគរចាំប្រឹងតស៊ូទប់ទល់នឹងពួកអ៊ីស្លាមយ៉ាងម៉ឺនម៉ាត់អត់ធន់ជាជាងអាណាចក្រឯទៀត ៗ ក្នុងឥណ្ឌា ហើយទើបតែបរាជ័យចាញ់ពួកអ៊ីស្លាម ក្នុងគ្រាដែលពួកអ៊ីស្លាមរួមកម្លាំងគ្នាចោមរោមចូលមកវាយ ទើបវិជយនគរធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃពួកអ៊ីស្លាម កាលពីពុទ្ធសករាជ ២១០៩ ។

នៅគ្រានេះហើយដែលប្រទេសឥណ្ឌាតាំងមូល ជាប្រទេសធ្លាប់ចំរើនរុងរឿងដោយអារ្យធម៌របស់ខ្លួនឯងមកជាយូរ ត្រូវធ្លាក់ទៅនៅក្នុងអំណាចរបស់ពួកមហាហ្ម័តបុអ៊ីស្លាម ហើយពង្សាវតាររបស់ឥណ្ឌាក៏ផ្លាស់ប្រែប្រួលប្លែកពីបុរាណកាល ព្រោះពុទ្ធសាសនាក៏សាបសូន្យបាត់អស់ទៅ នៅក្នុងឥណ្ឌាក៏កើតមានលទ្ធិសាសនា ២ ឡើង គឺសាសនាព្រាហ្មណ៍ដែលក្លាយមកជាសាសនាហិណ្ឌូ ១ សាសនាមហាហ្ម័តជាសាសនារបស់ពួកអ៊ីស្លាម ១ ។

សូម្បីបណ្ដានានាអាណាចក្រក្នុងឥណ្ឌានាំគ្នាលះបង់ចោលព្រះពុទ្ធសាសនាទៅហើយ តែនៅមានកោះៗមួយដែលដាច់ចេញពីផែនដីផ្ទាំងធំរបស់ឥណ្ឌា តាំងនៅក្នុងមហាសមុទ្រឥណ្ឌា មានផ្លូវឆ្លងគ្នាទឹងផែនដីផ្ទាំងធំបាននៅទិសខាងជើងកោះ ដែលយើងធ្លាប់ហៅថាកោះលង្កា ឬលង្កាទ្វីបៗ នេះនៅមានបក្ខពួកស្មោះត្រង់កាន់គោរពសាសនារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ កោះនេះហើយជាកន្លែងប្រតិស្ឋានសាខានៃមហាពោធិព្រឹក្ស ជាកន្លែងស្តុកស្តម្ភដោយគម្ពីរដីកានឹងព្រះសង្ឃសាវក ។

ដោយហេតុកោះលង្កានៅជាប់គុទឹងផែនដីផ្ទាំងធំរបស់ឥណ្ឌា ទើបប្រវត្តិសាស្ត្ររបស់កោះលង្កាមានខដែលគួរសង្កេតជា ២ ប្រការ គឺ កោះលង្កាបានទទួលប្រជាជនទឹងអារ្យៈធម៌មកអំពីឥណ្ឌា ដោយមានពួកទមិឡចូលមកអាស្រ័យនៅក្នុងកោះនេះជាចំនួនច្រើន ហើយបាននាំយកសាសនាព្រាហ្មណ៍ ទឹងពុទ្ធសាសនាមកផ្សាយផងនេះប្រការ ១ ប្រការ ១ ទៀត ដោយហេតុជាស្រុកកោះ ទើបរក្សាខ្លួនឲ្យបានគង់ទ្រង់នៅបាន មិនត្រូវពួកអ៊ីស្លាមចូលលុកលុយខ្ទេចខ្ទី ដូចជាអាណាចក្រទាំងឡាយក្នុងឥណ្ឌា តាំងអំពីសម័យព្រះបាទអសោកមហារាជរហូតមកដល់សព្វថ្ងៃនេះ ៗ ឯព្រះពុទ្ធសាសនាទុកជាត្រូវបៀតបៀនសង្កត់សង្កិនជាខ្លាំងក៏មិនបាត់សាបសូន្យទៅឡើយ ។

កោះលង្កាបានស្គាល់នឹងគោរពរាប់អានព្រះពុទ្ធសាសនា ដោយគេជានុគាមរបស់ព្រះបាទអសោកមហារាជ កាលរវាងពុទ្ធសករាជ ៣១៣ ។ ព្រះបាទទេវានម្បិយតិស្សៈ ព្រះមហាក្សត្រលង្កាអង្គដំបូងដែលបានប្រកាសព្រះអង្គជាពុទ្ធមាមកៈ ហើយទ្រង់ជួយទំនុកបំរុងព្រះពុទ្ធសាសនា កសាងព្រះវិហារសាលានឹងព្រះចេតិយឡើងជាចំនួនច្រើន ភាសាបាលីដែលជាភាសាសម្រាប់ប្រើក្នុងរាជការ ក្នុងរាជអាណាចក្ររបស់ព្រះបាទអសោកនោះ ក៏ក្លាយទៅជាភាសាយ៉ាងសំខាន់ជាវិនិយមរាប់អាននៃពុទ្ធសាសនិកជននៅកោះលង្កា ។ ឯកិច្ចការដ៏សំខាន់នៃក្សត្រលង្កាតៗមក ក៏ប្រកាន់យកការឧបត្ថម្ភទំនុកបំរុងព្រះពុទ្ធសាសនាជាសំខាន់ ហើយការដំកើងកិត្តិយសរបស់ទ្រង់គឺការកសាងវិហារសាលា ពុទ្ធចេតិយ ជាពុទ្ធបូជា ព្រះមហាក្សត្រអង្គណាទ្រង់កសាងទុកបានច្រើន ក៏មានកិត្តិយសច្រើន ហេតុនេះហើយបានជាមានបុរាណវត្ថុសំខាន់របស់ព្រះពុទ្ធសាសនា សឹងបានសម្រេចដោយគេជានុគាមរបស់ព្រះមហាក្សត្រលង្កាជាច្រើន ដូចព្រះបាទអភយទុស្ត ទ្រង់កសាងលោហៈប្រាសាទឡើង កាលពីពុទ្ធសករាជ ៤២៩ ព្រះបាទវដ្ដគាមនី ទ្រង់គ្រងរាជ្យក្នុងរវាងពីពុទ្ធសករាជ ៤៥៥ ដល់ពុទ្ធសករាជ ៥០៣ ទ្រង់បានកសាងវត្តអភយគិរី ។ អំណើះកាលតមក ទើបលទ្ធិមហាយាន បានកើតនឹងចំរើនឡើងយ៉ាងក្រៃពេកក្នុងប្រទេសឥណ្ឌា

ខាងជើង ហើយផ្សាយចូលទៅរហូតដល់ស្រុកចិនផង ។ ព្រះពុទ្ធសាសនាក្នុងកោះលង្កានេះ រកកល់បង់បែកខ្ញែកចេញជា ២ ពួក ១ ពួកគឺពួកអភយគិរីវិហារ ដែលមានយោបល់យល់ថា គួរធ្វើតាមបែបមហាយាន តែ ១ ពួកទៀត គឺពួកមហាវិហារយល់ថា គួររក្សាបែបផែនលទ្ធិហីនយានយ៉ាងម៉ឺងម៉ាត់ ។ ទាំង ២ គណៈនេះ ទៅជាកើតជជែកគ្នាតាស៊ូទែងគ្នាក្នុងរវាងគណៈសង្ឃទាំង ២ ពួក ។

ដោយហេតុកោះលង្កាតាំងពីដើមមក មិនដែលធ្វើការតាក់ទងនឹងការផែនដី ឬការរាជការនឹងប្រទេសឥណ្ឌា ព្រះចៅផែនដីរាជវង្សដំបូង ៗ ទើបមានឱកាសរវល់តែកិច្ចការក្នុងព្រះពុទ្ធសាសនាតែម្យ៉ាង ច្បាប់សម្រាប់ស្រុកទេសដែលព្រះមហាក្សត្រទ្រង់រៀបចំឡើង ក៏ព្យាយាមធ្វើតាមច្បាប់សីលធម៌របស់ព្រះពុទ្ធសាសនាគ្រប់យ៉ាង ដូចព្រះបាទអមនុគាមនីទ្រង់ចេញព្រះរាជប្រកាសហាម មិនឲ្យសម្លាប់សត្វគ្រប់បំពួកក្នុងកោះទាំងមូល តែច្បាប់នេះមិនបានស្ថិតស្ថេរប៉ុន្មានទេ កាលអស់បុណ្យក្សត្រនេះក៏លើកលែងប្រើទៅ ។ ក្នុងសម័យដែលប្រទេសឥណ្ឌាកើតចលាចលវរឹក ដោយការលុកលុយចូលមកនៃជនជាតិប្រទេសក្រៅនោះ ពួកពុទ្ធសាសនិកជនក៏បានអាស្រ័យជ្រកកោនកោះលង្កានេះឯងជាម្ចប់ ៗ ក្នុងបំពួកពុទ្ធសាសនិកជនដែលចូលមកជ្រកម្លប់នៅក្នុងកោះលង្កានោះ មានព្រះថេរៈសំខាន់ ១ អង្គឈ្មោះពុទ្ធឃោសាចារ្យ

កាលដើមឡើយនៅដែនមគធៈ ហើយចូលមកដល់កោះលង្កា កាលពីពុទ្ធសករាជ ៩៦៣ ក្នុងសម័យព្រះបាទមហានាមគ្រងក្រុងលង្កា ។ ព្រះពុទ្ធឃោសាចារ្យសំណាក់នៅក្នុងមហាវិហារបានតែងគម្ពីរទុកក្នុងព្រះពុទ្ធសាសនាជាច្រើន មានគម្ពីរយ៉ាងវិសេសមួយដែលជាស្នាដៃរបស់លោក គឺគម្ពីរវិសុទ្ធិមគ្គ ។ ព្រះពុទ្ធឃោសាចារ្យចេញពីកោះលង្កាតាំងអំពីពុទ្ធសករាជប៉ុន្មានមិនប្រាកដ គ្រាន់តែមានសេចក្តីដំណាលថា ចេញពីកោះលង្កាទៅប្រទេសភូមា ហើយតាំងអំពីនោះមក ភិក្ខុនៅកោះលង្កាតែងទៅមកប្រស្រ័យគ្នានឹងភិក្ខុនៅប្រទេស ភូមា, មន នឹងសៀម ។ លង្កាជាទីដំកល់ព្រះពុទ្ធសាសនាយ៉ាងមាំមួន តាមន័យដែលពោលមកនេះ សភាពរបស់កោះលង្កាជាទីស្ងប់ស្ងាត់ សមជាទីស្នាក់នៃអ្នកសន្តោស, អ្នកតែងនឹងអ្នកគិត ។

តែការប្រណាំងប្រជែង-ដាស់ទែងគ្នារវាងគណៈអភយគិរី នឹងគណៈមហាវិហារតែងតែមានជានិច្ច ។ លុះតមកដល់ពួកទមិឡមានអំណាចឡើង កោះលង្កាក៏ត្រូវពួកទមិឡអ្នកស្រុកការនែតចូលលុកលុយមុនពួកជនដទៃទៀត ហើយដោយហេតុពួកទមិឡកាន់សាសនាជេនិស្ទខ្លះ ហិណ្ឌូខ្លះ តែមិនបានកាន់ព្រះពុទ្ធសាសនាទេ កាលច្បាំងលុកមកដល់កោះលង្កាហើយ ទើបធ្វើបាបដល់ពុទ្ធសាសនិកជនជាខ្លាំង ហើយបំផ្លាញកំទេចចោលវត្តអស់ជាច្រើន ។ ក្នុងរវាងពុទ្ធសករាជ ១៤៥០ កោះ

លង្កាក៏ត្រូវពួកបន្ទុយៈនៃស្រុកមទុរៈចូលមកលុកលុយទៀត តមកក្នុងរាជ្យពុទ្ធសករាជ ១៥៤៨ ត្រូវក្សត្រគោលៈព្រះនាមរាជៈរាជ ចូលមកលុកលុយដល់កោះលង្កាទៀត កាលកោះលង្កាត្រូវសត្រូវខាងក្រៅចូលមកលុកលុយដូច្នោះ កិច្ចការព្រះសាសនាខាងក្នុងស្រុកក៏ត្រឡប់ជារួបរួមមូលគ្នាវិញ ,ហើយសម្រេចព្រមព្រៀងគ្នាថា ត្រូវឲ្យពួកមហាវិហារធ្វើជាធំ ទើបលទ្ធិហីនយានមានសេចក្ដីខ្ជាប់ខ្ជួនល្អ អ្នកដែលអាចធ្វើឲ្យគូវិវាទរួបរួមគ្នាបាននោះ គឺព្រះបាទបរក្រមពាហុទី ១ ដែលទ្រង់បានគ្រងរាជ្យតាំងអំពីពុទ្ធសករាជ ១៦៩៦ ដល់ពុទ្ធសករាជ ១៧២៧ ទ្រង់បានឲ្យប្រជុំសង្ឃនៅស្រុកអនុរាធបុរៈ កាលពីពុទ្ធសករាជ ១៧០៤ ហើយទ្រង់ប្រកាសឲ្យលើកលែងជជែកវិវាទគ្នាតទៅទៀត ទ្រង់ប្រកាសឲ្យមានសាមគ្គីរួបរួមគ្នា ហើយត្រូវប្រតិបត្តិតាមលទ្ធិហីនយានយ៉ាងម៉ឺងម៉ាត់ ៗ ព្រះបាទបរក្រមពាហុនេះ ទ្រទ្រង់ព្រះកិត្តិគុណថា ទ្រង់ជាព្រះមហាក្សត្រដែលមានព្រះទ័យជាកុសលបំផុត ទ្រង់បានកសាងមន្ទីរពេទ្យជាច្រើនអនេក ហើយទ្រង់ផ្ចាប់ក្បាជម្ងឺដោយព្រះអង្គឯងក៏មាន ទ្រង់កសាងស្តូបចេតិយ វិហារ, សាលា សុម្រាប់ជាលំនៅរបស់សង្ឃរាប់ដោយពាន់រូប ៗ

លុះមកដល់ព្រះពុទ្ធសករាជ ១៧៧៣ ទើបកោះលង្កាត្រូវពួកចោរហិណ្ឌូចូលមកលុកលុយញាំញីក្នុងគ្រាវិបត្តិនេះ ពួកពុទ្ធសាសនិកជនទាំង

ថាវត្តក្នុងព្រះពុទ្ធសាសនា ត្រូវទំលាយបំផ្លាញអស់ទៅជាច្រើន ។ កាលពួកចោរសមុទ្រចេញផុតទៅហើយ ទើបព្រះបាទវិជ័យពាហុទ្រង់ឲ្យជួសជុលថាវត្តដែលបាក់បែកទៅឡើងវិញ ក្នុងព្រះពុទ្ធសករាជ ១៧៩៣ ។ នៅគ្រានេះ ទ្រង់ឲ្យចាត់ការកសាងវិហារយ៉ាងធំឡើងនៅស្រុកគន្ធី សម្រាប់ជាទីបញ្ចុះព្រះទាឋធាតុរបស់ព្រះពុទ្ធជាម្ចាស់ ដរាបមកដល់សម័យសព្វថ្ងៃនេះ ។ ព្រះរាជឱរសរបស់ព្រះបាទវិជ័យ-ពាហុ ទ្រង់ព្រះនាមព្រះបាទបរក្រមពាហុទី ៣ ដែលទ្រង់បានគ្រងរាជ្យរហូតមកដល់ព្រះពុទ្ធសករាជ ១៨៤២ នេះក៏ជាព្រះរាជផែនដីសំខាន់ ១ អង្គដែរ ក្នុងប្រវត្តិសាស្ត្ររបស់លង្កា ទាំងចំណែកខាងស្រុកទេស ទាំងចំណែកខាងសាសនា ទ្រង់បានចាត់ការកសាងស្រុក ស្រីវឌ្ឍនបុរៈឡើង សាងស្ពាន, សាងផ្លូវថ្នល់ឡើងជាច្រើន ហើយមានសេចក្ដីដំណាលថា ទ្រង់ជាមហាក្សត្រដែលសព្វព្រះទ័យនឹងបុណ្យកុសលជាបំផុតរបស់លង្កា ទ្រង់បានឲ្យលើកលែងប្រើច្បាប់ប្រហារជីវិតចេញ ។ កាលព្រះបាទបរក្រមពាហុទី ៣ សោយទិវង្គតទៅហើយ ក្នុងពុទ្ធសករាជ ១៨៥៧ កោះលង្កាក៏ត្រូវពួកទមិឡអ្នកស្រុកការន័តចូលមកលុកលុយទៀត ក្នុងគ្រានេះឯង កោះលង្កាក៏ធ្លាក់ទៅនៅក្នុងអំណាចរបស់ពួកទមិឡពេញបន្ទុក ។ ពួកទមិឡមានអំណាចគ្រប់គ្រងនៅភាគខាងជើងរបស់កោះនេះទាំងអស់ ចំណែកពួកសីហឡ ( អ្នកស្រុកលង្កា ) គេងថយទៅ

នៅខាងត្បូង សេចក្ដីចំរើនរបស់កោះលង្កាក៏រៀររោយគាំងអំពីនោះមក ជាវត្ថុយ៉ាងល្អៗ ក៏បាក់បែកខូចខាតអន្តរាយទៅជាព្រៃបន្តិចម្ដងៗ តែនៅមានបុរាណវត្ថុខ្លះនៅគង់ទ្រង់ល្អមិនអន្តរាយទៅ គឺព្រះមហាពោធិព្រឹក្ស ដែលបានផ្សាំមែកមកដាំនោះ មានអាយុជាង ២០០០ ឆ្នាំហើយ. នៅមានមែកសាខាត្រឈឹងត្រឈៃជាអនុស្សាវរីយ៍ សម្រាប់ដឹកនាំចិត្តរបស់ពុទ្ធសាសនិកជនឲ្យកើតសេចក្ដីជ្រះថ្លារហូតមកដល់សព្វថ្ងៃនេះ ។

ចប់ប្រវត្តិសាស្ត្រប្រទេស ឥណ្ឌា ដោយសង្ខេបតែប៉ុណ្ណេះ

---

# រឿងសាមកុក

អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង .

(តមក)

===

ឯពួកអ្នកធ្វើបាយក្នុងជើងក្រាន ក៏បាននិយាយពិគ្រោះគ្នាថាយើងនឹងបង់មុខ ឬសម្លាប់តែម្ដងទៅ ចូឆ្ងបានឮដូច្នោះក៏តិះឆ្ងល់ក្នុងចិត្តទើបខ្សឹបសួរតាន់កុងថា ប៉ែះជៀនេះគេគ្រាន់តែជាក្មួយនិងចៅខ្ញុំ ពុំមែនជាញាតិសាច់អ្វីសោះ ប្រហែលគេចេញទៅប្រាប់មេស្រុកជំទប់ភ្នាក់ងារឃុំឲ្យមកចាប់យើងទេដឹង ទើបគេបង្គាប់ទុកឲ្យមនុស្សក្នុងផ្ទះចាំបង់មុខឬសម្លាប់តែម្ដងដូច្នោះ តាន់កុងថាខ្ញុំមិនគាប់ដឹង ព្រោះមិនបានស្គាល់ចិត្តប៉ែះជៀនោះសោះ ចូឆ្ងថាបើដូច្នោះយើងនឹងទុកចិត្តម្ដេចបាន ថាហើយក៏ហូតគ្រប់ដើរចូលទៅក្នុងផ្ទះ កាប់ការិយាបុត្រនិងមនុស្សម្នា ប៉ែះជៀស្លាប់អស់ ៨ នាក់ ។ តាន់កុងដើរទៅម្ខាងឃើញជ្រូកគេចងទុកក្នុងចំណង ក៏ស្លុតចិត្តគិតថាគេចងជ្រូកទុកនឹងសម្លាប់ធ្វើទេ ហេតុម្ដេចអ្នកសម្លាប់បុត្រការិយាប៉ែះជៀអស់ដូច្នេះខុសណាស់ ។ ចូឆ្ងក៏ហួសចិត្តគិតនឹកបារម្ភខ្លាចមិនគាប់បង្អង់នៅលើផ្ទះនោះ ក៏នាំតាន់កុងចុះពីលើផ្ទះជិះសេះបរប្រញាប់ទៅ លុះទៅបានប្រមាណ ២០ សិន (៨០០ ម៉ែត្រ). ទន្ទួលជួបនឹងប៉ែះជៀ ។ សួរថា ហេតុម្ដេចក្មួយមិននៅពិសាបាយសិន ប្រញាប់ទៅណា ។ ចូឆ្ងឆ្លើយថាខ្ញុំបានជាមនុស្សខុសហើយ នឹងស្រុត

ទៅឲ្យផុតរូបអំពីភ័យអន្តរាយ មាត់តែនិយាយសេះតែបរលឿនទៅត្រ-លប់គិតបត់សេះមកក្រោយវិញហៅថា មាឈប់សិនខ្ញុំផ្តាំពាក្យ ១ មាត់ទុក ប៉ែះឆៀក៏ឈប់ ៗ ចូឆូបរសេះទៅដល់ទន្លឹមក៏ហូតគ្រីកាប់ប៉ែះឆៀស្លាប់នៅទីនោះទៀត គាន់កុងឃើញដូច្នោះក៏រឹតតែស្លុតចិត្តគិតហើយនិយាយនឹងចូឆូថា កាលអម្បាញមិញនេះអ្នកសម្លាប់ត្រកិរិយានឹងមនុស្សម្នារបស់ប៉ែះឆៀស្លាប់អស់ទៅហើយ ឥឡូវនេះ ហេតុម្តេចមកសម្លាប់ប៉ែះឆៀទៀត ៗ ចូឆូឆ្លើយថាកាលអម្បាញមិញ យើងគិតច្រលំស្មានខ្លួនទៅហើយ បើនឹងទុកប៉ែះឆៀឲ្យនៅរស់នោះមុខជានឹងទៅប្រាប់មេស្រុកធំទប់ក្នាក់ងារឃុំ ឲ្យលើកគ្នាមកតាមចាប់យើងមិនខាន ហេតុនេះហើយយើងត្រូវតែសម្លាប់ប៉ែះឆៀចេញ ទើបស្ងប់ផុតរឿងដំណើរនេះមិនមានមកដល់យើង ៗ គាន់កុងឆ្លើយថា អ្នកគ្មានសេចក្តីគិតសោះប្រញាប់ទៅសម្លាប់គេគតខុស បើដឹងថាខ្លួនខុសហើយ មកថែមសម្លាប់គេទៀតដូច្នេះជាមនុស្សអកតញ្ញូមិនល្អទេ ៗ ចូឆូថាអ្នកនិយាយនេះក៏ត្រូវហើយ តែធម្មតាកើតមកជាមនុស្សតែងនឹងស្រឡាញ់រក្សាខ្លួនឲ្យបានសេចក្តីសុខ មិនត្រូវឲ្យអ្នកដទៃប្រទុស្សរាយបាន ៗ ជាខ្ញុំធ្វើដូច្នេះ និយាយហើយក៏នាំគ្នាបរសេះទៅដល់ទីតំណាក់មួយក៏នាំគ្នាចូលទៅសំណាក់ដេកនៅទីនោះ កាលចូឆូដេកលក់ស៊ប់ គាន់-កុងក៏ក្រោកអង្គុយរំពឹងគិតថា ខ្លួនអញហៅពេញចោលម្សៀតណាស់

តាំងចិត្តកាត់លះបុណ្យស័ក្តិទ្រព្យសម្បត្តិចេញ ព្រោះស្រឡាញ់រាប់អានប្អូន ដោយស្មានថាមនុស្សនេះល្អត្រឹមត្រូវប្រាកដនឹងបានសន្មតយកគ្នាជាចិត្តគំនិតមួយ ជួយឧបត្ថម្ភទំនុកបំរុងគ្នាតទៅ តែតដឹងថាប្អូនជាមនុស្សអាក្រក់ជួជាតិសាមាន្យ គ្មានសេចក្តីកតញ្ញូដល់អ្នកមានគុណូបការៈសោះ បើដូច្នោះអញនឹងស្មគ្រសមាគមរួមចិត្តគំនិតជាមួយគេទៅឃើញថាពុំបាន គួរតែនឹងសម្លាប់បោលចេញកុំឲ្យមានភ័យបារម្ភតទៅ គិតហើយក៏ហូតគ្រីបចេញមកនឹងសម្លាប់ប្អូនក៏ឯយទៅគិតវិញថាហេតុទាំងនេះមិនពីព្រោះនរណា ព្រោះតែខ្លួនអញត្រូវចិត្តគំនិតនឹងគេមកពីដំបូងបានជាតាមគេមក បើប្អូនៈដ៏ខុសនឹងសម្លាប់ចេញក៏មិនមានផ្លូវចំណេញអ្វីមកពីអញ បើមិនគាប់ចិត្តស្រឡាញ់ត្រូវតែគេយកខ្លួនឲ្យរួចទៅជាជាង គិតហើយតានកុងក៏ក្រោកភ្លាមចងសេះជិះបរទាំងយប់ទៅនៅស្រុកតាំងកុង ។

ប្អូនលុះភ្ញាក់ពីដេកក្រឡេកទៅមិនឃើញតានកុង ក៏គិតថាតានកុងឃើញធ្វើខុសទើបដោះខ្លួនរត់បោលអញដូច្នេះ បើពេញនឹងនៅក្នុងទីនេះក៏នឹងមិនរួចអំពីភ័យ គិតហើយក៏ក្រោកឡើងចងសេះជិះទៅទាំងយប់នោះលុះដល់ស្រុកតាន់លីវ ក៏ចូលទៅរកៈចាកោជាបិតា ពណ៌នារឿងរ៉ាវប្រាប់សព្វគ្រប់ប្រការ ហើយថាដែលខ្ញុំរត់មកនេះប្រាថ្នានឹងសុំមាសប្រាក់របស់បិតាយកទៅទិញសេះនឹងគ្រឿងសស្ត្រាវុធ ដើម្បីបញ្ចុះបញ្ចូល

មនុស្សឲ្យបានជាពួកម៉ាកច្រើន ហើយនឹងធ្វើការយកគាសាផែនដីតទៅ ទៅកោះធ្វើយថា ទ្រព្យសម្បត្តិយើងមានខ្លះដែរ តែមិនដូននឹងបាត់ការបាន កុងស្រុកនេះ យើងឃើញមនុស្សម្នាក់ឈ្មោះអ៊ុយហងមានទ្រព្យសម្បត្តិច្រើនណាស់ចិត្តក៏ធូរទូលាយហើយត្រង់នឹងផែនដី បើកូនយកហេតុនេះទៅប្រាប់ដល់គេៗក៏ជួយទំនុកបំរុងខ្លះមិនខាន ៈ កូនក៏មុខជានឹងបានទិញសេះនឹងគ្រឿងសស្ត្រាវុធតាមប្រាថ្នា ។

ចូឆ្ងបានពុងណឹងបិតាឲ្យដូច្នោះក៏អរណាស់ ទើបបង្គាប់ឲ្យរៀបចំណីអាហារ ហើយឲ្យទៅអញ្ជើញអ៊ុយហងមកពិសាបាយ ចូឆ្ងក៏និយាយពីយរឿងឲ្យអ៊ុយហងស្តាប់សេចក្តីថា សព្វថ្ងៃនេះគាំងតុៈទុច្ចរិតគិតធ្វើការពុជការជាលាមកអាក្រក់គឺសត្រូវនឹងផែនដីខ្លាំងណាស់ ខ្ញុំបាទឈឺចិត្តគិតចំសូះស្វែងមកទាំងម៉្លេះនេះ ពីព្រោះតែប្រាថ្នានឹងយកគាសាផែនដីប្រយោជន៍ដើម្បីនឹងរំលាយបំផ្លាញគាំងតុៈនោះចេញ តែថាកំឡាំងទ្រព្យសម្បត្តិរបស់ខ្ញុំមានតិចណាស់ ទើបកៀសខ្វះមករកចបាយនឹងបញ្ចុះបញ្ចូលពួកម៉ាកឲ្យបានច្រើន ហើយនឹងលើកជាកងទ័ពគ្រឡប់ចូលទៅច្បាំងនឹងគាំងតុៈ បើទុកជាយ៉ាងណាក៏ត្រូវសម្លាប់ពាំឲ្យបាន តឡូវខ្ញុំបាទបានពុងណឹងថា លោកមានទ្រព្យសម្បត្តិជាច្រើន មានទាំងសន្តានចិត្តសុចរិតត្រង់នឹងផែនដី ខ្ញុំបាទនឹងសុំខ្ចីប្រាក់លោកយកទៅទិញគ្រឿងប្រដាប់ចម្បាំង គឺសេះនឹងគ្រឿងសស្ត្រាវុធនានានឹងបានធ្វើការតទៅ ។

អ៊ុយហង់បានស្តាប់ក៏ចាប់ចិត្តត្រេកអរណាស់ថា តាំងពីខ្ញុំបានពុំដំណឹងថាស្រុកក្រុងកើតចលាចល ក៏មានតែសេចក្តីខ្វាយខ្វល់នឹងចង់ទំនុកបំរុងផែនដី តែគ្មានខណៈណាមកប្រាជ្ញប្រាប់សេចក្តីឲ្យចូលចិត្តសោះ ឥឡូវបានអ្នកមកបំភ្លឺឲ្យខ្ញុំយល់ នោះខ្ញុំមានសេចក្តីត្រេកអរណាស់ ទ្រព្យសម្បត្តិរបស់ខ្ញុំមានមិនខ្វះ ខ្ញុំអាចហានប្រគល់ឲ្យអ្នកចាត់ចែងតាមត្រូវការ ។

ចូឆូមានសេចក្តីត្រេកអរណាស់ ទើបធ្វើទង់ជ័យសមួយបន្ទះ ហើយសរសេរអក្សរកណ្តាលទង់ថា ឲ្យមនុស្សទាំងពួងមានចិត្តសុចរិតទៀងត្រង់នឹងផែនដី ហើយដោតទង់នោះនៅចំពោះមុខផ្ទះ បណ្តាអ្នកស្រុកទាំងពួង ដល់បានឃើញទង់នឹងអក្សរដូច្នោះ ក៏នាំគ្នាចូលមកនៅជាពួកក្រុមចូឆូច្រើនណាស់ ចូឆូក៏បេះតែបញ្ចុះបញ្ចូលជាមនុស្សចុះចូលជាច្រើន ។

គ្រានោះមានឈ្មោះហៃហ៊ូទុនជាបង ហៃហ៊ូអៀនជាប្អូននៅស្រុកថៃកុក ឯហៃហ៊ូទុននោះកាលពីអាយុ ១៤ ឆ្នាំ ទៅរៀនចំណេះតាហានក្នុងសំណាក់គ្រូ ១ មានកូនសិស្សម្នាក់មាក់ងាយគ្រូ ហៃហ៊ូទុនខឹងក៏សម្លាប់ឈ្មោះនោះស្លាប់ ហើយរត់ទៅនៅចុងស្រុក លុះដឹងដំណឹងថាចូឆូឲ្យបញ្ចុះបញ្ចូលមនុស្សជាកងទ័ពដូច្នោះ ក៏បញ្ចុះបញ្ចូលពួកក្រុមបានមួយពាន់ផ្ទាយ ហើយនាំហៃហ៊ូអៀនជាប្អូនទៅនៅជាពួកចូឆូ ។

ឯប្រាយមិនទឹងពោហងបងប្អូន ២ នាក់ ក៏នាំពួកពលបានមួយពាន់ផ្កាយទៅជាមួយនឹងឆាកដិននៅស្រុកឃុងបេង លិតៀននៅស្រុកសានយុងទាំងអស់គ្នា ក៏ចូលទៅនៅជាមួយនឹងចូឆូ គ្រានោះអ៊ុយហង់ឃើញបណ្តាអ្នកស្រុកនាំពួកម៉ាកទៅនៅនឹងចូឆូជាច្រើនដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់ ទើបយកមាសប្រាក់ទៅឲ្យចូឆូវិញ សេះនឹងគ្រឿងសស្ត្រាវុធសម្រាប់ការសង្គ្រាមចំរើនឡើងពល់ ១ ថ្ងៃ បណ្តាអ្នកស្រុកទាំងប្រុសស្រីក៏បបួលគ្នានាំយកសេះនឹងគ្រឿងសារុធនូវស្រូវអង្ករស្បៀងអាហារទៅឲ្យចូឆូជាច្រើន ឯចូឆូក៏រីងរិតតែមានសេចក្តីត្រេកអរសប្បាយរីករាយឡើង ទើបឲ្យសង់រោងសម្រាប់ជាទីប្រជុំខុរាជការនឹងសេនាទាហានជួបជុំនិយាយការខាងសឹកសង្គ្រាមតាមពេលព្រឹកល្ងាច បណ្តាសេនាទាហាន សឹងមានគ្រូហ៊ឹកហាត់នូវស្នៀតគុនអាវុធមុតមាំពុំមានខានមួយថ្ងៃ ។

ឯអ្នកសៀវផ្លែគាំងតុៈល្អូងល្ហងលោមយកចិត្ត តាំងទុកជាទីចៅហ្វាយស្រុកពុតហៃ លុះត្តដំណឹងថា ចូឆូប្រមូលពួកក្រុមបានច្រើន ក៏ប្រឹក្សានឹងក្រុមការទាំងពួងថា យើងនឹងលើកពលទាហានទៅចូលនៅជាពួកចូឆូផង សេនាទាហានទាំងនោះក៏ឃើញត្រូវផង ទើបអ្នកសៀវក៏លើកគងយោធាទៅរួបរួមចូលជាពួកចូឆូ ៣ ម៉ឺនផ្កាយ ឯចូឆូលុះឃើញអ្នកសៀវលើកពលមកជាពួកកងដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់

ចេញមកប្រឹក្សានឹងអ្នកស្រុកថា ឥឡូវនេះ យើងប្រជុំគ្នាធ្វើការធំមាំមួនណាស់ ត្រូវតែធ្វើសំបុត្រព្រះតម្រាស់ប្រាប់ទៅគ្រប់ខេត្តខណ្ឌ ជាសេចក្ដីបញ្ចុះបញ្ចូលឲ្យមូលមករួបរួមនឹងយើងទើបស្រួល អ្នកស្រុកយល់ព្រមក៏តែងជាសំបុត្រព្រះតម្រាស់ព្រះចៅហៀនគេ សេចក្ដីថាទ្រង់ត្រាស់ប្រើបុច្ចុឲ្យលបចេញមកប្រកាស អស់បណ្ដាចៅហ្វាយខេត្តខណ្ឌក្នុងព្រះរាជអាណាចក្រ ចូរឲ្យបានដឹងគ្រប់គ្នា ដ្បិតសព្វថ្ងៃនេះ បណ្ដាខាហ៊ុនតូចធំនឹងអាណាប្រជានុកស្រុកក្នុងព្រះនគរ មានសេចក្ដីក្ដៅក្រហាយណាស់ ព្រោះតាំងតុជាសត្រូវរាជសម្បត្តិក្បត់សម្លាប់ហាង់ដូពៀន ដែលជាព្រះជេដ្ឋាក្ស័យព្រះជន្មទៅ ហើយលើកយើងឲ្យសោយរាជ្យជាម្ចាស់ផែនដីបីដូចជាអ្នកតា តាំងខ្លួនក៏ជាមហាឧបរាជមានអំណាចកាន់កាប់មុខងាររាជការផែនដីស្រេចលើខ្លួនក៏ទាំងអស់ មានតែបុច្ចុជាមនុស្សក្រតញ្ញូ ស៊ីបូរាជរិតក្រោមព្រះបាទ មានចិត្តឧបាតសង្វាត ចំធ្វើរាជការជាសុចរិតទៀងត្រង់ប្រាកដ បានសាបាលស្បថចំពោះព្រះភក្ត្រថានឹងយកអាសារំលាងតាំងតុដែលជាសត្រូវរាជសម្បត្តិចេញឲ្យបានជាដាច់ ។

ខណៈនោះចៅហ្វាយខេត្តទាំង ១៥ មណ្ឌលដែលជាធំគឺអ្នកស៊ុតចៅហ្វាយស្រុកលាំយុង ១ ហ័នហ៊ុកចៅហ្វាយស្រុកគិដីរ ១ ខុងម៉ចៅហ្វាយស្រុកសៀងដីរ ១ ឡៅតាយចៅហ្វាយស្រុកអ៊ីវដីរ ១ អងខងចៅហ្វាយស្រុកបោឡាយ ១ ទៀវម៉ៅ ចៅហ្វាយស្រុកគាន់លីវ ១

តៀវប៉ោ ចៅហ្វាយស្រុកតង់គុន ១  អួនអ៊ុយ ចៅហ្វាយស្រុកស៊ិនយុង ១ ហ្វាសិន ចៅហ្វាយស្រុកបេប៉ាក ១  ខុងឡេង ចៅហ្វាយស្រុកប៉ាកហៃ ១ តៀវបៀវ ចៅហ្វាយស្រុកកងឡេង ១  គោគៀម ចៅហ្វាយស្រុកឈីដីវ ១ ម៉ាថេង ចៅហ្វាយស្រុកសេលៀង ១  តៀវអៀង ចៅហ្វាយស្រុកសៀង-គុង ១  ស៊ួនគៀន ចៅហ្វាយស្រុកទៀងសា ១  បានទទួលសំបុត្រព្រះ-តម្រាស់បានដឹងច្បាស់សេចក្តីហើយ  ក៏មានសេចក្តីត្រេកអរទាំងអស់គ្នា ទើបចាត់ការឃុំនាំពលយោធាខែត្រនិមួយ ៗ ខ្លះ ១ ម៉ឺន ខ្លះ ២ ម៉ឺន ខ្លះ ៣ ម៉ឺន  លើកទៅបញ្ចូលជាមួយនឹងកងទ័ព បូច្ចូ រួមជា ១៦ ខែត្រនឹង អួនសៀវ បូច្ចូ ក៏លើកប្រមូលកងទ័ពទាំងអស់នោះទៅដល់ព្រំដែនស្រុក ឡុកអៀង ជាទីក្រុង ៗ

គ្រានោះ  ឈ្មោះកងស៊ុនចាន់ចៅហ្វាយស្រុកប៊ុកប៉េងឮដំណឹងថា មានព្រះតម្រាស់ដូច្នោះ ក៏ប្រមូលអាហារបានមួយម៉ឺនប្រាំពាន់លើកទៅ ដល់ខែត្រចេងតួនគួន ដែលឡៅពីឈរក្សា ឯឡៅពីដឹងថាកងស៊ុនចាន លើកអាហារមក ក៏នាំគួនអ៊ូ តៀវហ៊ុយ ចេញទៅទទួលដល់ទ្វារស្រុកកង ស៊ុនចានក៏ម្នាគំនាប់ហើយសួរថា - ដែលបានមកជាមួយ ២ នាក់នោះ ឈ្មោះអ្វី មកនេះប្រាថ្នានឹងទៅណា ? ឡៅពីឆ្លើយថានោះឈ្មោះគួនអ៊ូ នោះឈ្មោះតៀវហ៊ុយ  អាហារសេះរបស់ខ្ញុំកាន់ផ្ទុសរ  គឺជាប្អូនខ្ញុំទាំង ២ នាក់ខ្លាំងពូកែណាស់  ដែលអ្នកមានគុណឧបការនឹងខ្ញុំពីដើមនោះខ្ញុំឮថា

អ្នកលើកទ័ពមកផ្លូវនេះបានជាចេញមកទទួល ប្រាថ្នានឹងអញ្ជើញអ្នកទៅឈប់ស្នាក់សម្រាកកំឡាំងទាហាន ១ វេលា កងស៊ុនចានបានស្ដាប់ក៏នឹកឃើញថាគួនអ៊ូតៀវហ៊ុយ ហើយក៏ចូលទៅក្នុងស្រុកផេងខ្ទួនគួន . ទើបនិយាយនឹងទៀតថា គួនអ៊ូតៀវហ៊ុយនេះបានទៅជួយច្បាំង នឹងពួកចោរជួតក្បាលលឿងមានថ្វីដៃល្អ តែនឹងរកអ្នកឯណាជួយស្ញើសរសើរគុណបំណាច់ឲ្យគ្មានបានជានៅជាទាហានឡើវដូច្នេះ លុះនិយាយហើយក៏អធិប្បាយពីព្រះតម្រាស់ដែលត្រាស់ប្រើចុះ ឲ្យចេញមកប្រកាសដល់បណ្ដាខែត្រទាំងពួងឲ្យឡើតស្ដាប់ ហើយបបួលទៀតថា សព្វថ្ងៃនេះអ្នកបានជាទីចៅហ្វាយស្រុកហើយ តែជាស្រុកតូចណាស់ ពេលនេះចូរអ្នកទៅជាមួយនឹងយើងចុះ បើសម្រេចការហើយ ខ្លួនអ្នកនឹងប្អូនអ្នកទាំង ២ នាក់ មិនលែងបានជាចៅហ្វាយស្រុកខែត្រឯកទេ ទៀតពីមានសេចក្ដីត្រេកអរណាស់ ក៏ស្រុះស្រួលទទួលពាក្យនឹងកងស៊ុនចាន តៀវហ៊ុយឆ្លើយថាកាលទៅច្បាំងនឹងពួកចោរជួតក្បាលលឿងនោះ ខ្ញុំឃើញកិរិយាតាំងតុ:ជាមនុស្សអាក្រក់ មិនជាអ្នកស្គាល់ទោសនឹងគុណសោះ ខ្ញុំប្រុងនឹងសម្លាប់វាចេញ បងចេះតែឃាត់ខ្ញុំ បើកុំតែបងឃាត់ប្រហែលមិនមានរឿងធំដូច្នេះទេ គួនអ៊ូក៏ឃាត់តៀវហ៊ុយថា កុំឲ្យនិយាយថ្វី ឥឡូវយើងបានទៅជាមួយនឹងកងស៊ុនចានហើយ គង់បានប្រទះគ្នាទៀតទេ ខ្ញុំអរណាស់ទៀតពីក៏ឲ្យរៀបចាត់ចែងទាហាន រើសយកតែមនុស្សណាដែលជាទំនុក

ទុកចិត្ត លុះរើសបានរួចស្រេចហើយ កងស៊ុនចាននឹងឡៀវពី គួនអ៊ូ តៀវហ៊ុយ ក៏លើកកងទ័ពទៅដល់ប្រទល់ដែននឹងក្រុងឡកអៀង ។

ឯចូជូនឹងចៅហ្វាយខែត្រទាំងពួង ក៏ឲ្យតាំងបន្ទាយរាយកងទ័ពជាប់គ្នាជាលំដាប់ទៅ ផ្លូវនៅឆ្ងាយពីក្រុងប្រហែល ២០០សិន (៨ គីឡូ-ម៉ែត្រ ) ចូជូឲ្យរៀបតុតាំងលៀងភោជនាហារ បណ្តាចៅហ្វាយខែត្រទាំងអស់សឹងមកស៊ីលៀងព្រមគ្នា លុះបរិភោគរួចវេលាណា ក៏ចាត់ការនឹងឲ្យលើកទាហានចូលវាយក្រុងឡកអៀង អងទងនិយាយឡើងថា ឥឡូវនេះ យើងរាល់គ្នាសុទ្ធតែគតញ្ញូនឹងផែនដី ទើបនាំគ្នាចូលមកប្រជុំធ្វើការនេះ យើងមិនមានតាំងអ្នកឯណាឲ្យកាន់អាជ្ញាសិទ្ធិជាធំនឹងបង្គាប់បញ្ជានាយកងនាយពលសោះ បើដូច្នេះឃើញថា នឹងលើកចូលទៅវាយនោះនៅមិនទាន់បានទេ ចូជូបានស្តាប់ក៏ចាប់ចិត្តគិតឃើញត្រូវ ទើបនិយាយប្រកាសថា អ្នកសៀវនោះជាមនុស្សមានពូជពង្សវង្សត្រកូលជានាហ្មឺនរៀងមកដល់ ៤ ត ៥ តហើយ គួរនឹងលើកឲ្យធ្វើជាមេទ័ពធំកាន់អាជ្ញាសិទ្ធិបង្គាប់បញ្ជានាយកងនាយទ័ពទាំងពួង តើអ្នកទាំងអស់យល់ឃើញដូចម្តេច? (មន្ត្រីខែត្រទាំងអស់ក៏បានទទួលយល់ព្រម) តែអ្នកសៀវបែរជាមិនទទួលតំណែងនេះ ចៅហ្វាយខែត្រទាំងអស់ទាស់អង្វរស្រ័យគ្នាថា បើអ្នកសៀវមិនព្រមទទួលធ្វើជាមេទ័ពធំទេ ឃើញថានឹងរើសរកតទៅទៀតមិនបាន បើដូច្នេះតើនឹងត្រូវធ្វើដូចម្តេច? ឯអ្នកសៀវ

ឃើញថាមិនស្រួល ក៏ព្រមទទួលធ្វើជាមេទ័ពធំក្នុងពេលនោះ ប៊ូធូក៏ឲ្យសង់ពេនធំ ១ សម្រាប់អ្នកសៀវចេញនិយាយការពេជការក្នុងបន្ទាយ លុះដល់ថ្ងៃមានឫក្សជោគជ័យល្អ ក៏អញ្ជើញអ្នកសៀវឲ្យឡើងអង្គុយលើទីជំសមគួរ ហើយប៊ូធូនឹងហៅហ្វាយខែត្រទាំង ១៧ មណ្ឌល ក៏ដំកល់គ្រឿងសក្ការៈអុចទៀនធូបបួងសួងទេវតាអារក្សផឹកទឹកពិភពទួសប្ចា សន្មតថានឹងតាំងចិត្តជាសុចរិតទៀងត្រង់នឹងផែនដីតទៅ ប៊ូធូទើបចាក់ស្រាគំនាប់ហៅហ្វាយខែត្រទាំងពួង ផឹកហើយក៏និយាយថា យើងនឹងធ្វើសង្គ្រាមធំគ្រានេះ មិនត្រូវបែកចិត្តគ្នាឲ្យខូចការទេ ប្រូមានចិត្តជាពិតត្រង់នឹងគ្នាទើបធ្វើការនោះនឹងបានសម្រេចដោយស្រួលងាយ ។

អ្នកសៀវឆ្លើយថា តម្រេះប្រាជ្ញាយើងក៏នៅជាប្រមាណ ដែលអ្នកទាំងអស់ស្រះចិត្តគ្នាលើកឲ្យយើងធ្វើជាមេទ័ពធំនោះ យើងក៏ត្រូវធ្វើតាមអាជ្ញាសិទ្ធិនឹងទំនៀមច្បាប់ពិជ័យសង្គ្រាម បើអ្នកឯណាមានគុណគាប់ប្រសប់ធ្វើការ យើងក៏ត្រូវឲ្យបំណាច់រង្វាន់ទាន់ចិត្ត បើអ្នកឯណាទុច្ចរិតប្រព្រឹត្តខុស យើងក៏ត្រូវចុះទោសតាមច្បាប់អយ្យការសឹក អ្នកទាំងអស់គ្នាបានស្តាប់ហើយកុំប្រកួចចិត្តនឹងយើងឡើយ ប៊ូធូនឹងហៅហ្វាយខែត្រទាំង ១៧ មណ្ឌលក៏ទទួលយល់ព្រម អ្នកសៀវទើបចាត់ឲ្យអ្នកស៊ុតជាប្អូនធ្វើមេទ័ពណូនសម្រាប់បញ្ជូនស្បៀងអាហារកុំឲ្យដាច់ ចាត់ស៊ុនគៀនមេទ័ពមុខលើកទាហានចេញទៅវាយតយកទីស៊ុយគួន ស៊ុនគៀនក៏លើកទាហានទៅតាំងបន្ទាយជាប់នឹងគយនោះ ។

ឯនាយគយលុះឃើញដូច្នោះ ក៏ធ្វើសំបុត្របកឲ្យបំរើសេះនាំចូលទៅប្តឹងដល់ស្រុកក្រុង លើយូបានដឹងការ ក៏នាំសេចក្តីនោះទៅជំរាបតាំងគុះ ស្លុតចិត្តភិតភ័យណាស់ ទើបប្រឹក្សានឹងលើយូថា គោនេះ នឹងបានអ្នកឯណាយកអាសា ចេញទៅតតាំងច្បាំងចាប់យកស៊ុនកៀន ឲ្យបាន លើប៉ៅឆ្លើយថា ដែលចៅហ្វាយខែត្រលើកពលចូលមកទាំងនេះ ប្រៀបដូចមមាច ខ្ញុំបាទនឹងសូមយកអាសាលើកកងទ័ពចេញទៅសម្លាប់ឲ្យបាន លោកកុំបីមានចិត្តគិតព្រួយបារម្ភឡើយ តាំងគុះបានស្តាប់ដូច្នោះហើយ ក៏អរសរិត្តក្រីកមុខពេះពាយ ទើបនិយាយថា សព្វថ្ងៃនេះយើងបានលើប៉ៅមកទុកជាបុត្របិញ្ចឹម ក៏នឹកស្ងើមថា បើនឹងបានទាហានដទៃដប់-ម៉ឺន ក៏មិនគួរស្មើនឹងមនុស្សម្នាក់នេះឡើយ ខណៈនោះមានទាហានម្នាក់ឈ្មោះហ៊ុយហ៊ុង ទ្រង់ទ្រាយដូចខ្លាកំពស់ ៦ ហត្ថបាយ លុះបានឮលើប៉ៅអួតខ្លួនដូច្នោះ ក៏លុតជង្គង់សំពះតាំងគុះហើយថា ដែលនឹងសម្លាប់មាន់ មិនត្រូវទៅកាន់កាំបិតដែលសម្លាប់គោយកទៅសម្លាប់មាន់ទេ ការគ្រានេះ គ្រាន់តែត្រឹមចៅហ្វាយខែត្រទាំងពួងលើកទ័ពមកប៉ុណ្ណោះ មិនបាច់នឹងឲ្យលើប៉ៅជាបុត្រលោកលើកពលទៅតាំងច្បាំងឲ្យលំបាកទេ តែត្រឹមខ្ញុំបាទក៏សូមយកអាសាចេញទៅកាត់ក្បាលចៅហ្វាយខែត្រទាំងអស់មកជូនលោកបានហើយ តាំងគុះបានស្តាប់ក៏ពេញចិត្តណាស់ ទើបឲ្យហ៊ុយហ៊ុងឡើងជានាយទាហានធំ ហើយចាត់ទាហានឲ្យហ៊ុយហ៊ុង ៥ ម៉ឺនចេញទៅ

ជាមួយនឹងលំសុក ១ ហោជីន ១ តៀវឆិម ១ ទាំង ៤ នាយលើកចេញទៅ ឯហួយុងទីងនាយទាហានទាំង ៣ លើកពលទាំងប្រាំម៉ឺនស្រុតត្រូវចេញទៅតាំងបន្ទាយនៅគយកំស៊ុយកួន ។

ខណៈនោះចៅស៊ុន ដែលនៅក្នុងវ័ពក្នុងសៀវ គិតថាស៊ុនកៀន ជាមេទ័ពមុខលើកពលទៅកាយបន្ទាយកំស៊ុយគួននោះ បើបានការ ក៏មានសេចក្ដីគាប់ប្រសើរតែលើស៊ុនកៀនម្នាក់ឯង ទើបបាត់បែងឲ្យចៅគុង ជាប្អូននាំទាហានចេញទៅមួយផ្លូវទៀត ប្រយោជន៍ឲ្យស្រុកកាយបន្ទាយកំស៊ុយកួនឲ្យបានជាមុន សេចក្ដីគាប់ចិត្តនឹងត្រឡប់បានមកខាងខ្លួន ក៏បានបាត់ការស្រេចឲ្យចៅគុងលើកទ័ពចេញទៅ លុះដល់ទល់គ្នាហើយ ក៏បរពលឲ្យចូលកាយបន្ទាយជាមុនស៊ុនកៀន ។

ឯហួយុងឃើញដូច្នោះ ក៏ដេញទាហានប្រាំរយបើកទ្វារបន្ទាយចេញមក ហើយស្រែកឲ្យចៅគុងថា ខ្លួនជាពួកចោរមកតតាំងច្បាំងនឹងអញឬ? ចៅគុងបានឮក៏បែរមុខទៅឃើញហួយុងមានសេចក្ដីភ័យណាស់ ញាក់សេះបរត្រឡប់ទៅខាងក្រោយ ហួយុងក៏បរសេះដេញបណ្ដោយតាមយកដាវកាប់ត្រូវចៅគុងធ្លាក់ពីលើសេះស្លាប់ ចាប់បានទាហានឈ្លើយជាច្រើន ហើយឲ្យកាត់យកក្បាលចៅគុងដាក់ចាំងបកសំបុត្របញ្ជូនចូលទៅឲ្យតាំងតុកងស្រុកក្រុង តាំងតុមានសេចក្ដីត្រេកអរណាស់ ក៏ឆ្លើយតបសំបុត្រមកតាំងហួយុងជាទីនាហ្មឺនធំ ។

ចំណែកស៊ុនគៀនមានទាហានទៅជាមួយ ៤ នាក់ ឈ្មោះគៀវផៅ កាន់លំពែង ១ អ៊ុយកាយកាន់ដំបងដែក ១ មានមុខស្រួច ៤ ហ័នតុងកាន់ដាវ ១ ចូម៉ៅកាន់ដាវវែងមួយម្ខាង ស៊ុនគៀនគែងខ្លួនពាក់ក្រោះហើយកាន់ដាវវែង នាំពួកទាហានចេញទៅឈរនៅមុខបន្ទាយហើយស្រែកថា អាពួកក្បត់ អាឯងចូរបើកទ្វារចេញមកតយុទ្ធនឹងអញជាប្រញាប់ បើបង្អង់យូរអញនឹងហែកបន្ទាយចូលទៅកាត់ក្បាលឲ្យអស់ឥឡូវនេះ ហោជិនបានឮដូច្នោះ ក៏និយាយនឹងហួយុងថា ខ្ញុំបាទសុំទាហាន ៥០០០ ចេញទៅយកអាសារលោកជាមុន ហួយុងក៏ចាត់ទាហានឲ្យហោជិនហើយបើកទ្វារចេញទៅ ។

គៀវផៅឃើញហោជិនចេញមក ក៏ឡើងសេះកាន់លំពែងចេញទៅទទួលតនឹងហោជិនបាន ៧ ក្បួន គៀវផៅយកលំពែងចាក់ត្រូវហោជិនធ្លាក់ពីលើសេះស្លាប់ ទាហានក៏ដេញប្រកាប់ចូលទៅចាក់កាប់សំឡាប់ទាហានហោជិនទល់នឹងជើងកំពែង ។

ហួយុងឃើញបរាជ័យ ក៏ឲ្យទាហានឡើងលើខ្នងកំពែងបាញ់ធ្នូសរចោលដុំថ្មធ្លាក់ចុះទៅត្រូវទាហានស៊ុនគៀនបែកបាក់ពិការជាច្រើន ស៊ុនគៀនយល់ថានឹងវាយទំលាយពុំបាន ក៏ឲ្យទាហានថយក្រោយមកវិញ ហើយតាំងបន្ទាយនៅតំបន់លៀងតុង ទើបឲ្យបកសំបុត្រតាមដំណើរចូលទៅស្នើឲ្យអួនសៀវផ្ញើសេចក្តី សំបុត្រមួយបកទៅដល់អ៊ុនស៊ុតជាមេទ័ពល្ហូនឲ្យបញ្ជូនស្បៀងអាហារមកឲ្យពួកពលទាហានបរិភោគជាប្រញាប់ ។

# ប្រវត្តិព្រះអានន្ទត្ថេរ

ហ្វ៊ុនទិពន្ធមន្ត្រី ញ៉ុក - ថែម ប្រែនិងរៀបរៀង

---

ព្រះអានន្ទត្ថេរ ជាព្រះឱរសរបស់ស្តេចសុក្កោទនសក្យរាជ ដែលជាព្រះកនិដ្ឋភាតារបស់ព្រះបាទសុទ្ធោទនរាជ ក្នុងក្រុងកបិលពស្តុ ព្រះមាតាព្រះនាមថា ព្រះនាងកិសាគោតមី បើរាប់រៀងតាមលំដាប់សាក្យវង្ស ខ្លួនលោកត្រូវជាព្រះអនុជរបស់ព្រះបរមសាស្តា ។ គ្រាកាលដែលព្រះបរមសាស្តាប្រថាប់នៅឯអនុបិយនិគមដែនមល្លក្សត្រនោះ ព្រះអានន្ទសក្យរាជ ក៏បានចេញទៅបួសព្រមជាមួយនឹងសក្យរាជអង្គដទៃទៀត គឺ ព្រះភទ្ទិយ, អនុរុទ្ធ, ភគុ, កិម្ពិល, កោលិយវង្សមួយ គឺព្រះទេវទត្ត រួមជា ៧ នឹងឧបាលីជាខ្មាន់ព្រះកេស ។ កាលព្រះអានន្ទសក្យរាជ បានឧបសម្បទាហើយ បានស្តាប់ធម៌ដែលព្រះបុណ្ណមន្តានីបុត្រពោលទូន្មាន ក៏បានសំរេចសោតាបត្តិផល ។ កន្លងសម័យថ្ងៃ ១ ព្រះបរមសាស្តាទ្រង់ត្រាស់សុំឲ្យព្រះសង្ឃជ្រើសរើសភិក្ខុ ដែលត្រូវនៅបំរើព្រះអង្គជាប់ជានិច្ច ដ្បិតកាលពីមុននេះ ភិក្ខុដែលមកឧបដ្ឋាកបំរើព្រះអង្គ ច្រើនតែផ្លាស់ប្តូរមិនទៀងទាត់ វេលាដែលផ្លាស់ទៅ មិនមានអ្នកទទួលជំនួស គោងព្រះអង្គគង់នៅតែមួយព្រះអង្គ បានសេចក្តីលំបាកក៏មាន ទើបព្រះសង្ឃជំនុំជ្រើសរើសព្រះអានន្ទថ្វាយព្រះបរមសាស្តា តែមុនលោកទទួលនាទីជាពុទ្ធុបដ្ឋាក ព្រះអានន្ទត្ថេរបានក្រាបទូលសុំពរ ៨ ប្រការថា :

១ សូមកុំប្រទានចីវរដ៏ប្រណីតដល់ខ្ញុំព្រះអង្គ ។

២ សូមកុំប្រទានបិណ្ឌបាតដ៏ប្រណីតដល់ខ្ញុំព្រះអង្គ ។

៣ សូមកុំឲ្យខ្ញុំព្រះអង្គនៅក្នុងទីប្រថាប់ជាមួយនឹងព្រះអង្គ ។

៤ សូមកុំនាំខ្ញុំព្រះអង្គទៅកាន់ទីនិមន្ត ។

៥ សូមព្រះអង្គស្ដេចយាងទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គបានទទួលទុក ។

៦ សូមអនុញ្ញាតឲ្យខ្ញុំព្រះអង្គនាំបរិស័ទ្យដែលចូលមកគាល់ពីឆ្ងាយ ចូលគាល់ព្រះអង្គបាន ក្នុងខណៈដែលមកដល់ ។

៧ បើសេចក្ដីសង្ស័យកើតឡើងដល់ខ្ញុំព្រះអង្គវេលាណា សូមឲ្យខ្ញុំព្រះអង្គចូលគាល់ទូលសួរបាន ក្នុងវេលានោះ ។

៨ បើព្រះអង្គទ្រង់សំដែងធម៌ទេសនារឿងអ្វីមួយ ក្នុងទីកំបាំងមុខខ្ញុំព្រះអង្គ សូមព្រះអង្គសំដែងប្រាប់រឿងនោះដល់ខ្ញុំព្រះអង្គកុំខាន ។

ព្រះបរមសាស្ដាត្រាស់សួរថា ម្នាលអានន្ទ ចុះអ្នកឃើញគុណនិងទោសដូចម្ដេច ទើបអ្នកសូមយ៉ាងនេះ ។ ព្រះអានន្ទត្ថេរក្រាបបង្គំទូលថា បើខ្ញុំព្រះអង្គមិនបានពរ ៤ ប្រការខាងដើមទេ នឹងមានពាក្យគេបោ និន្ទាថា ព្រះអានន្ទបានទទួលលាភសក្ការៈយ៉ាងនេះ ៗ បានជាខំទំនុកបំរុងព្រះបរមសាស្ដា ការបំរុងបំរើយ៉ាងនេះ នឹងធ្ងន់ប៉ុន្មានទៅ ។ ប្រសិនបើខ្ញុំព្រះអង្គ មិនបានទទួលពរ ៣ ប្រការខាងចុងទេ មនុស្សទាំងឡាយ

នឹងនិយាយបានថា ព្រះអានន្ទទំនុកបំរុងព្រះបរមសាស្ដាធ្វើអ្វី ព្រោះព្រះអង្គមិនទ្រង់អនុគ្រោះដោយកិច្ចត្រឹមប៉ុណ្ណឹង ។ បើសិនបើខ្ញុំព្រះអង្គមិនបានទទួលពរទាំងបួនបង្អស់ទេ បើមានគេសួរខ្ញុំព្រះអង្គក្នុងទីកំបាំងព្រះភក្ត្រថា ធម៌នេះព្រះអង្គទ្រង់សំដែងក្នុងទីណា បើខ្ញុំព្រះអង្គសំដែងប្រាប់គេមិនបានទេ គេនឹងពោលតិះដៀលថា លោកមិនដឹងត្រឹមរឿងប៉ុណ្ណឹង បំណាច់ដើរតាមព្រះបរមសាស្ដា ដូចជាស្រមោលអន្ទោលតាមប្រាណ អស់កាលយូរអង្វែង ។ លុះព្រះអានន្ទត្ថេរក្រាបបង្គំទូលពីគុណនិងទោស នៃពរទាំង ៨ ប្រការយ៉ាងនេះហើយ ព្រះបរមសាស្ដាក៏ទ្រង់អនុញ្ញាតឲ្យតាមសេចក្ដីសុំគ្រប់ប្រការ ។ តាំងអំពីកាលណោះមក ព្រះអានន្ទត្ថេរ ក៏ឧបដ្ឋាកព្រះបរមសាស្ដា ដោយសេចក្ដីគោរព ហើយមានចិត្តស្មោះត្រង់ចំពោះព្រះអង្គជាយ៉ាងក្រៃពេក ត្រាតែហ៊ានលះបង់ជីវិតថ្វាយព្រះបរមសាស្ដាបាន ដូចមានឧទាហរណ៍ថា កាលព្រះបាទអជាតសត្រូវ ទ្រង់ឲ្យលែងដំរីនាឡាគិរី ដែលកំពុងចុះប្រេងឲ្យមកធ្វើអន្តរាយដល់ព្រះបរមសាស្ដា ព្រះអានន្ទត្ថេរនិមន្តទៅឈរនៅខាងមុខដំរី មិនឲ្យធ្វើអន្តរាយដល់ព្រះអង្គបាន ។ ដោយហេតុតែលោកនៅជិតជាប់នឹងព្រះបរមសាស្ដាមិនដែលឃ្លាត ទើបលោកបានស្ដាប់ធម៌ដែលទ្រង់សំដែងដល់ខ្លួនលោកនិងអ្នកដទៃ មានស្មារតីចងចាំទុកបានច្រើន មានសេចក្ដីព្យាយាមយកចិត្តទុកដាក់ស្វាធ្យាយរៀនសូត្រចងចាំ

ទុក ហើយជាអ្នកឈ្លាសវៃ ក្នុងការសំដែងធម៌ណាស់ ទើបព្រះបរមសាស្តាទ្រង់សរសើរលោកថា ជាអ្នកប្រសើរលើសលែងភិក្ខុទាំងឡាយ ៥ ស្ថាន គឺជាពហុស្សូត្រ ១ មានសតិ ១ មានគតិ ១ មានព្យាយាម ១ ជាពុទ្ធុបដ្ឋាក ១ ។ មួយវិញទៀត អាស្រ័យគុណធម៌ដែលលោកជាពហុស្សូត្រនេះឯង កាលព្រះអង្គបរិនិព្វានទៅហើយ ទើបព្រះមហាកស្សបត្ថេរ កាលផ្តើមធ្វើបឋមសង្គាយនាព្រះធម្មវិន័យ ព្រះសង្ឃទាំងពួងបានជ្រើសរើសលោកឲ្យជាអ្នកវិសជ្ជនា ទាំងសុត្តន្តបិដក ទាំងអភិធម្មបិដក ។ ព្រះអានន្ទត្ថេរនេះ បានសម្រេចអរហត្តផល ក្នុងវេលាព្រឹកមុនថ្ងៃដែលសង្ឃប្រជុំធ្វើសង្គាយនាបន្តិច ដូចមានសេចក្តីដំណាលថា មុនថ្ងៃដែលសង្ឃប្រជុំធ្វើសង្គាយនាមួយថ្ងៃ លោកបានទទួលសេចក្តីដាស់តឿនអំពីព្រះមហាកស្សបត្ថេរ ឲ្យខំបំពេញព្យាយាម លុះដល់វេលាល្ងាច លោកក៏ខំចំរើនសមណធម៌ ត្រាតែបានសម្រេចព្រះអរហត្តផល ក្នុងចន្លោះឥរិយាបថទាំង ៤ ។ លុះអំណើះកាលតមក លោកពិចារណាឃើញអាយុសង្ខាររបស់លោក ជិតដល់ពេលបរិនិព្វានហើយ ទើបលោកនិមន្តទៅកាន់ស្ទឹងរោហិនី ដែលជារពង់ព្រំប្រទល់វង្សសក្យវង្សនឹងកោលិយវង្ស មុននឹងបរិនិព្វាន លោកបានហោះឡើងទៅលើអាកាស សំដែងធម្មទេសនាទូន្មានដល់ពួកមនុស្សនិងពួកទេវតា វេលាចប់

ទេសនា ទ្រង់សំដែងឥទ្ធិវិទ្ធិមានប្រការៈផ្សេងៗ ទើបតាំងសត្យាធិដ្ឋានថា កាលអាត្មានិព្វានហើយ សូមឲ្យរាងកាយរបស់អាត្មាអញ បែងចែកចេញជាពីរចំណែក ហើយធ្លាក់ចុះទៅខាងត្រើយព្រះញាតិសក្យវង្សមួយចំណែក ខាងត្រើយព្រះញាតិកោលិយវង្សមួយចំណែក ដើម្បីមិនឲ្យព្រះញាតិទាំងសងខាងកើតវិវាទទាស់ទែងគ្នា ព្រោះហេតុអដ្ឋធាតុរបស់អាត្មាអញ ។ លុះអធិដ្ឋានស្រេចហើយ ក៏លោករំលត់ខន្ធចូលកាន់បរិនិព្វានក្នុងអាកាសវេហាស៍ នាពាក់កណ្ដាលស្ទឹងរោហិនី សរីរៈរាងកាយក៏បែងចែកចេញជាពីរចំណែក ហើយធ្លាក់មកផែនដីជាពីរចំណែក សមដូចសេចក្ដីអធិដ្ឋានគ្រប់ប្រការ ។

ចប់ប្រវត្តិសង្ខេបព្រះអានន្ទត្ថេរតែប៉ុណ្ណោះ (១) ។

---

(១) ព្រះអានន្ទត្ថេរ កាលបើពិនិត្យមើលប្រវត្តិរបស់លោកនឹងឃើញប្លែកពីព្រះសាវកឯទៀតៗ ទាំងអស់ ដោយកិលេសនិព្វាន នឹងខន្ធនិព្វាន ។ គឺព្រះសាវកឯទៀតៗ បានត្រាស់ដឹងនិព្វាន ក្នុងឥរិយាបថទាំង ៤ គឺដេកដើរឈរអង្គុយ ឥរិយាបថណានីមួយ ។ ឯព្រះអានន្ទត្ថេរ បានត្រាស់ដឹងក្នុងចន្លោះឥរិយាបថទាំង ៤ ឈ្មោះថាខុសពីសាវកដទៃ ១ ដោយកិលេសនិព្វាន ។ លោករំលត់ខន្ធបរិនិព្វានលើអាកាស ឈ្មោះថាខុសពីសាវកដទៃ ដោយខន្ធនិព្វាន ។

✓ ច្បាប់ក្រម ហាមណោរ

ហ្លួងទិពន្ធមន្ត្រី ញ៉ុក - ថែម រៀបរៀង

---

បទពាក្យគតិ

នេះគឺព្រះច្បាប់ ទុកជាសណ្ដាប់ ខ្ញុំទានអ្នកផង គឺព្រះបន្ទូល មធុរសាសន៍ ច្បាប់នេះកន្លង លែងច្បាប់ទាំងឡាយ ៗ ព្រះអង្គ គង់នា ជេតពនហៅវិហារ វិសេសពណ្ណរាយ ស្ដែងស្ដេចទេសនា ដោយបទបរិយាយ អាមាត្យទាំងឡាយ វិសេសជាធំ ៗ ទោះទាំង ទេវតា មនុស្សសត្វផងណា ចូលមកបង្គំ ក្រញុំក្រាបត្រង់ត្រាប់ ស្ដាប់ច្បាប់ឧត្ដម ដោយនូវក្រិត្យក្រម ពីព្រះឱស្ឋា ៗ ហៃជនទាំង-ឡាយ ចូរស្ដាប់អភិប្រាយ ទុកនៅអាត្មា ស្រូវរៀនទុកក្នុង កំឡុង វ័យា គួរគប្បីមហា ជនផងត្រង់ត្រាប់ ៗ កើតកង់លោកីយ៍ ឲ្យ ដឹងសេចក្ដី ឆាំក្ដង់ខុសគាប់ ទោះខ្សត់ទោះមាន ទោះរស់ទោះស្លាប់ ឲ្យធ្វើដោយច្បាប់ តាមព្រះពុទ្ធដីកា ៗ កើតមកជាមនុស្ស ទោះ ស្រីទោះប្រុស លោកឲ្យអនិច្ចា អំពីកំណើត កាលកើតមកណា សឹងមានវេទ ពៀរពុំឃាតឡើយ ៗ អ្នកឯណាកើតមក រស់រូបរូបល្អ បានបរិបូណ៌ហើយ ម្ដាយខ្ញុំមរក្សា សព្វថ្ងៃជាត្រើយ កុំភ្លេចគុណឡើយ ទុកលើសិរសា ៗ វគុណឪពុក ឲ្យដឹកលំទុក ប្រហែលមាតា គុណ

ញាតិសន្តាន ផៅពង្សវង្សា ជីដូនជីតា សឹងមានគុណផង ៗ ឲ្យខុនលំអុត រក្សាផ្គងផ្គត់ កុំឲ្យមានហ្មង លុះដំដឹងក្តី ដប់ពីរហើយហោង ចាំបើកខ្លួន អំពីនោះណា ៗ បាន ១២ ឆ្នាំ ឲ្យបងចិត្តចាំ គិតក្នុងអាត្មា នៅជាគ្រហស្ថ ពុំបានឡើយណា ឲ្យគិតអនិច្ចា ហើយទៅបួសហោង ៗ បួសគ្រឯណា បរិបូណ៌បានជា សាមណេរហើយផ្គង ចិត្តចាំបួសរៀន រៀនធម៌ផង កុំបារឃ្នើសឃ្នង ឃ្នើសពុំខ្លាចគ្រូ ៗ កុំសើចកុំលេង រក្សាខ្លួនឯង ឲ្យដឹងខុសត្រូវ ដឹងបុណ្យដឹងបាប ដកបរៀងទៅ ទោះបេះទោះខ្ចៅ តាមដោយកសនា ៗ ប្រដៅសេចក្តី ទោះកក់ព្រៅទ្វី ឲ្យចាំពុទ្ធដីកា កត់ទុកនៅក្នុង កំឡុងទ័យា ទុកស្មើកែវជា រក្សាខ្លួនហោង ៗ បួសនោះបំរើ ដោយនៅអំពើ ទីងក្រិត្យក្រមសង្ឃ កុំឲ្យលោកខ្ញាល់ សំបារដៅផង កុំឲ្យមានហ្មង ខុសទីងព្រះវ័យ ៗ ទោះល្ងាចទោះព្រឹក ឲ្យមានចិត្តទឹក ជាអាចិន្ត្រៃយ៍ កុំដេកលទ់លក់ ស្រមុកដល់ថ្ងៃ រាំសារៃ ដោះឡើងម្ទើមម្ទា ៗ ដណ្តាំបង្ហាន់ ទឹកស្រង់ទឹកឆាន់ ទឹកស្ងួតក្តីណា រក្សារង់គោក ម្ជូរម្ជូធាកស្វា សង្ហាត់ឧស្សាហ៍ ផ្កាប់ផ្គូនប្រក្រតី ៗ ឲ្យលោកកាស្ទូរ អាណិតស្រោកស្រួល ទីងជីសត្វថ្ងៃ បុណ្យទៅបរលោក បុណ្យក្នុងលោកិយ៍ សឹងបានដូចនៃ ចិត្តដ៏ប្រាថ្នា ៗ ថាបើលោកអាក់ ពុំស្ងួតក់ទាក់ ទីងដីឡើយណា កុំឲ្យលោកទាយ ទំនាយពុំជា ខ្លួនជីសោតណា មុខជា

សៅហ្មង ៗ ពាក្យគ្រុតឆាប់ បំផ្លូចផ្កាប់ ដែកពេជ្រជាម្ដង ពុំដែល
រសាយ រលាយឡើយហោង ដូចកលបំណង ពុំដែលឃ្លាតឃ្លា ៗ
លោកមានអំណាច ឲ្យប្រាកោតខ្លាច អត់ធនសិរសា ប្វាត់ប្វាយបង្គំ
ប្រណម្យវន្ទា លាទោសអាត្មា និងគ្រូនោះហោង ៗ ដីបួសយូរទៅ
ទោះប្រាជ្ញទោះខ្លៅ ដោយនៅគន្លង តាមដោយគម្ពីរ ព្រះវិន័យហោង
កុំឆ្ងើរលង ព្រះវិន័យណា ៗ បើចង់ទៅផ្ទះ ករចូលសំពះ បង្គំក្រាបលា
បានត្រៃចីវរ ចីពរពាក់ស្មា សិស្សគណគ្គា កំដររទៅផង ៗ នោះទើប
ហៅសង្ឃ ទោះរៀចទោះត្រង់ តាមដោយគន្លង បានជាបន្ទាល់
សាក្សីខ្លួនហោង ដោយនូវគន្លង ព្រះពុទ្ធសាសនា ៗ កុំដើរម្នាក់ឯង
បង់បោយគ្រវែង គ្រីញាក់ស្មា លោកសង្ឃបោរាណ ត្រងោល
ពុំជា ដើរគគ្គីគា កំដររទៅផង ៗ យល់សព្វអំពើ ឧបាសកធ្វើ ទុក្ខ
ទោសពិត្តផង ពុំពាក្យអាស្រូវ ពុំត្រូវគន្លង ទោះទេព្ដាអង្គ ដេរពោល
ដំគ្គា ៗ អាបត្តិបាបនោះ ធ្លាក់ទៅចំពោះ ដូចដល់អាត្មា ធ្លាក់ទៅនរក
រងទុក្ខវេទនា ទីងនាំអាត្មា ពុំបានឡើយហោង ៗ ហើយទីងនាំម្ដាយ
សាច់ញាតិទាំងឡាយ ទៅនរកក្តុង លោកីយ៍ត្រមោច ហិនហោចទ្រព្យ
ផង ពុំបានដូចប៉ង បំណង់ប្រាថ្នា ៗ បើទីងចង់ដើរ ដោយនូវ
ដំណើរ តាមបទតំរិយា យកស្បង់ចីពរ បវរហៅមហា-បំសុកូលនោះ
ណា មកឃ្មុំស្រែចហោង ៗ កាន់ផ្ចិតនូវបែត ធ្វើឲ្យស្រគត់ ស្ពាយ

បាត្រខ្ទង់ បេញទៅយកបាត្រ ប្រោសអស់សត្វផង កុំឲ្យផ្តាំផ្តង ដោយពុទ្ធវិបារណ៍ ៗ អ្នកបួសនោះក្រ ធ្វើចិត្តឲ្យល្អ នាំញាតិកា នាំម្តាយ ឪពុក ទៅទុកនៅនា បានសុខសួស្តី បរិបូណ៌ពណ្ណកាយ ៗ ចាំហៃកិកុផង បុរអ្នកគ្រាប់ត្រង់ ក្រិត្យក្រមទាំងឡាយ រក្សាសីលផ្នួស ស្មើឪពុកម្តាយ កុំឲ្យអន្តរាយ សីលផ្នួសឡើយណា ៗ ឲ្យត្រង់ឲ្យស្លូត ពាក្យពេចន៍កុំកួត មុសាវាទា ស្រដីឲ្យត្រង់ ធ្ងន់ចិត្តឲ្យជា តាមដោយបុត្រា បំណាំងព្រេង ព្រឹទ្ធ ៗ អ្នកកុំសប្បាយ លេងសើចរីករាយ ឲ្យធ្ងន់គំនិត ដឹងពាក់ដឹងជ្រៅ ដោយទូរសុចរិត ឲ្យគន់ឲ្យគិត ដឹងគុណលោកផង ៗ គុណគ្រូបាធ្យាយ គុណអាពុកម្តាយ ធ្ងន់ក្រៃកន្លង ធ្ងន់ស្មើក្រឡា-ប្រថពីឯងហោង រកអ្វី ទឹងស្នង គុណពុំបានណា ៗ ឲ្យចំសង្វាត បំរើនស្ទឹងស្ទាធ៍ មេត្តាភាវនា ចំស្ត្រចំរៀន រៀនសាស្ត្រា ប្រយោជន៍អាត្មា ឯងទៅឯមុខ ៗ កុំ ឲ្យខ្ជិបខ្សៀវ កកែះកកៀវ សំឡឹងសំឡក់ ទោះទ្រព្យតិចច្រើន ទោះ ល្អអាក្រក់ ឈើព្រៃគេទុក សព្វទិសទីផង ៗ កុំលួចកុំយក កុំប្លន់ឆក់មក បៀតបៀនគ្នាផ្ទង នោះឯងហៅខុស ពុំដោយគន្លង កុំឲ្យចូលផង ទឹងអ្នក នោះណា ៗ អ្នកឯងនោះ ខ្ញុំឃ្លាតបំពោះ ទ្រព្យគេពុំជា អំពាលំនៅ យក ទៅនានា លោកហៅចត្តា-ដេយ្យចោរផង ៗ អាបត្តិធ្ងន់ពេក បីដូចថ្ម បែក សោះសូន្យជាម្តង លោកឲ្យប្រែប្រាស់ លាកលះចេញផ្តង កុំឲ្យ ចូលផង ទឹងអ្នកនោះឡើយ ៗ រក្សាកងវៃ ឲ្យដឹងយប់ថ្ងៃ កុំធ្វើគោះតើយ គ្រូលោកប្រដៅ ដោយទូវធម៌ហើយ កុំធ្វើឲ្យឈ្លើយ ខុសទឹងពុទ្ធដីកា ៗ

បើខុសនឹងគ្រូ ឲ្យលោកគ្រូជួរ ក្រែរក្រោងវាយថា ខ្លួនដ៏អសោច៍ ខ្ញុំ
កេរ្តិ៍ពុំជា លុះដល់មរណា ខ្ញុំខ្លួនជាម្តង ៗ មួយសោកដីការ កុំឲ្យលោក
ខ្ញាល់ ទ្រគោះខឹងផង ផ្សិតលោកមានគុណ មហាធ្ងន់ក្ងន់ នឹងរកអ្វីសង
គុណពុំបានណា ៗ ធ្វើឲ្យបរិសុទ្ធ ទទអង្គលំអុត ការកេរ្តិ៍អ្នកជា
បំណាច់អ្នកបួស សាងផ្សងផលា សំណាក់សាសនា កូតកលំលាយ ៗ
ទីងឲ្យមានជា មេត្រីស្នេហា នឹងគ្រូបាធ្យាយ កុំធ្វើចិត្តកាច កំណាច
មាក់ងាយ ទ្រស្តគ្រូបាធ្យាយ ពុំជាឡើយហោង ៗ ស្រដីឲ្យទៀង កុំឲ្យ
មានល្បៀង ពាក្យពេចន៍សាសង ដោយពិតដោយត្រង់ ត្រូវតាមគន្លង
កុំឲ្យមានហ្ន៎ង មន្ទិលឡើយណា ៗ កុំធ្វើចិត្តកាច ចចេសពុំខ្លាច
កក្កុតមាយា ស្រដីកុំល្បៀង ឲ្យទៀងសត្យា តាមពុទ្ធដីកា ប្រាកដពុំ
វែង ៗ កុំធ្វើបន្ទាល់ ចិត្តចង់ស្រើបស្រាល បន្ទុសគេឯង ឲ្យ
រក្សាខ្លួន ដោយក្បួនជាក់ស្តែង ឲ្យគិតកោតក្រែង នូវអ្នកមានគុណ ៗ
កុំងោយចិត្តពាល កុំទៅស្នេហ៍ស្នាល នឹងអ្នកឥតធន នឹងអ្នកកំសត់
ទុគតិតគបុណ្យ កុំសេពសម្ពន្ធ មូលជាមិត្តផង ៗ វានឹងបត្រ រលាយ
ស្រុកស្រុត ខ្លួនដូច្នោះហោង វានឹងរេចរិល គ្រនិលជាម្តង កុំចូលចិត្តចង
នឹងអ្នកនោះណា ៗ ខ្ញុំគេពុំគាប់ កុំទៅប្រសព្វ ជាមិត្តស្នេហា វា
នឹងអន្តរាយ ខ្ញុំខ្លួនអស្ចារ ខ្សត់ដូច្នោះណា ប្រាកដពុំឃ្លាត ៗ ថា
បើនឹងទៅ ជាមិត្តជាផៅ ឲ្យមើលមារយាទ មើលពង្សសន្តាន ឲ្យ

បានជាខ្នាត ចួបចូលសន្ធាត ជាមិត្រស្នេហា ។ បរិបូណ៌បានទ្រព្យ
បានដូចបង្គាប់ បានយសសក្តា គេស្រមក្សាន្តស្រណុក ឥតទុក្ខភ័យា
ដូចអ្នកនោះណា ពុំលែងឡើយហោង ។ រក្សាខ្លួនប្រាណ ដីកុំឲ្យមាន
មន្ទិលសៅហ្មង ស្មៀកស្បង់យកត្រៃ ចីវរគ្រប់គ្រង រាក់លើស៊ុំង
កុំឲ្យឃ្លាតឃ្លា ។ សង្ឃខ្លះចិត្តចោរ យល់ក្បាលត្រងោល ស្រូវកប្រោរ
ស្បង់យកមកដូត ធ្វើសាស្នាដូចជា បង់ក្បិនក្រទា ក្រតើនដើរទៅ ។
ខ្លះស្មៀកលយធាយ ដើរលេងកែក្រាយ ចេញផ្ចិតខាងក្រៅ បង្កសងខាង
ដូចឈ្មោងប្រែកនៅ នោះចាំដើរទៅ ពុំគិតគេថា ។ ម្នាក់ឯងឯកអោក
ស្មើរស្មុះស្មើរឈ្នោក រក្បាលញាក់ស្មា ដាក់កន្ទៀងផ្អួង ពុំត្រូវក្រិត្យា
គុណវិន័យថា សង្ឃចោរអប្រិយ៍ ។ ទាយកឯងណា មានចិត្តថ្លៃថ្លា
សទ្ធាប្រក្រតី ទីងនិទានទៅ ពុំសូវប្រៃពៃ ដ្បិតសង្ឃនោះនៃ ពុំត្រូវ
ក្រិត្តិកា ។ ថាបើបួសនៅ នោះប្រាជ្ញទោះខ្ញៅ ធ្វើចិត្តឲ្យជា កុំឲ្យមាន
ល្អៀង ជ្រេជ្រៀងឡើយណា តាមដោយពុទ្ធដីកា គ្រូលោកប្រដៅ
សង្ឃខ្លះបើង ប្រែប្រាណខេរខឹង ប្រទូស្តដើរទៅ ស្រដីបញ្ញាត បំ-
ពោតសៅដៅ ក្រឡេកក្រឡៅ ទឹងគ្រូនោះណា ។ បុណ្យគ្រូខ្ញាំង
ណាស់ ទុកស្មើអម្ចាស់ បង្កើតសិរសា ព្រះលោកបង្កើត ហើយមាន-
ទេវតា ទេព្រក្សរក្សា ចំរើនប្រក្រតី ។ គឺទេពសន្តត ឲ្យលោកប្រា-
កដ ត្រូតត្រាស្រដី លើអស់ភិក្ខុថេរ សាមណេរផងក្តី ចិត្តឯងអប្រិយ៍ •

ថាលោកពុំគាប់ ៗ ត្រូវដូចអន្ទង់ ដែលធំសំពង់ រាយលើទន្ទាប់ ចង់
ឲ្យបានត្រូវ បេះដឹងក្បួនច្បាប់ ចង់ឲ្យបានទ្រព្យ ដូចលោកទាំងឡាយ ៗ
នរអ្នកណា មានចិត្តមោហា ទ្រុស្តលោកបាធ្យាយ ទ្រុស្តមិត្រសំឡាញ់
ទ្រុស្តអាពុកម្តាយ អ្នកនោះអន្តរាយ ខូចអង្គអាត្មា ៗ នាគង់លោកិយ
បរលោកនោះក្តី ពុំបានជាការ មានទោសមានទុក្ខ ដូនណាសមហិមា
ពុំបានជាការ ឥតបានស្រាន្តស្រាក ៗ គេចងចាប់ជា ច្រើនដងច្រើន
គ្រា កើតខ្សត់លំបាក កំព្រាត្រមោច លន្លោចគោកយ៉ក ដ្បិតចិត្តពុំ
ស្រាក ទ្រុស្តគ្រូបាធ្យាយ ៗ ស្លាប់ទៅនរក ពិបាករងទុក្ខ ពុំបាន
រសាយ ភ្លើងឆេះពីក្រោម ទរលោមព្រានព្រាយ នៅអវិចិនាយ
ម្នាក់ឯងកំព្រា ៗ ហេតុចិត្តឆ្កួតខុស បាបដូនបំពោះ បន្ទោសអ្នកណា
ទទួលរងភ័យ អវិចិវេទនា ទាំងប្អូនធំជា ទោសដំក្លាត់ហោង ៗ អ្នកណា
ចិត្តស្លូត ពុំបេះគរក្លូត មុសាពទជង ទោះបីបួសនៅ សឹកទៅក្តីហោង
ចាំពុទ្ធដីកាថ្កូង គ្រូលោកប្រដៅ ៗ អក្សរបានបេះ របៀនចំណេះ
ប្រាជ្ញាយកទៅ បំរើក្សត្រា តម្រាក្បួននៅ អ្នកកុំធ្លាកនៅ ទីងច្បាប់នេះ
ណា ៗ លោកជាគម្ពង់ អក្សរនោះឯង បិតកងអាត្មា នេះហើយហៅថា
ញាតិនៅពង្សា បងប្អូនកូនជា ខ្ទួនឯងមុខមាត់ ៗ ទោះលោកស្រឡាញ់
ថាវែងបំពេញ ហទ័យផ្គេកផ្គិត កុំព្រួយពុទ្ធដីកា ចិន្តានោះថ្វាត់ កុំឲ្យ

ទាយទាត់ ទំនាយពុំសុខ ៗ ឲ្យព្រួយពុទ្ធដីកា អផ្សុកចិន្ដា ឲ្យលោក ជាទុក្ខ ស្រក់ទឹកព្រះនេត្រ វាចាអផ្សុក អ្នកច្បាប់កាន់ទុ នោះឯង ប្រែពា ៗ ថាបើត្រង់ពិត ចួបចូលក្នុងចិត្ត មូលមិត្រថ្លាថ្លៃ កុំបីឲ្យក្ដង ឲ្យ ហ្មងព្រះទ័យ បានបរិបូណ៌ក្រៃ ដូចចិត្តប្រាថ្នា ៗ ទោះដីទីនេះទៅ បំរើគាល់ ហៅ ព្រះមហាក្សត្រា លោកអ្នកមានបុណ្យ ទ្រព្យធនជាៗ បានដូច ប្រាថ្នា ពុំឃ្លាតបំណង ៗ បេះរៀនបេះដឹង គំនិតឲ្យទីង ដឹងគុណ លោកផង ឲ្យរក្សាខ្លួន ទីងនួនទៅហោង អ្នកពាលភ្លាំភ្លង ដីកុំស្មេ-ហា ៗ ពោលអ្នកមានគុណ ទៅសេពមេថុន មិត្រក្លាស្នេហា ខ្លួនដី ទីងខូច អស់ពូជពង្សា ទុកជាភ្លៃធ្លា ពុំជាប្រយោជន៍ ៗ វាទីងកើត ខ្សត់ សម្បត្តិទុគ៌ត កំព្រាត្រមោច អាសោច៍ខ្លួនដី . សមទីងផ្សាខ្លោច លន្លង់លន្លោច លំបាកអាត្មា ៗ មួយសោតពាក្យពេចន៍ ស្រដីឲ្យតិច ខន្តីប្រាជ្ញ ថាកាចដោយកាច ថាជាដោយជា ស្រដីត្រង់ណា មែន ត្រង់នោះហោង ៗ មាត្រាព្រះច្បាប់ ក្រមសាមណេរគាប់ ជួយជួស ពាក្យផង ជួយថែមពាក្យពេចន៍ តាមកិច្ចគន្លង ពាក្យលោកនេះហោង បរិបូណ៌ចែងចប់ ៗ

ច្បាប់ក្រមសាមណេរចប់តែប៉ុណ្ណោះ ។

# អំពីតាំងចៅអធិការថ្មី
## (តមក)

សញ្ញាប័ត្រលេខ ៤៩២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ នៅ នាមឆាយា គន្ធសរ កើតឆ្នាំ ១៩០០ អាយុ ៤៨ វស្សា ២៨ ជាចៅអធិការ វត្តចិន ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុន-សួន នាមឆាយា វិនយសុត្តា កើតឆ្នាំ ១៩២៣ អាយុ ២៥ វស្សា ៦ ជាចៅអធិការ វត្តក្រាំងដើម ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-គង់ នាមឆាយា គន្ធប្បញ្ញោ កើតឆ្នាំ ១៩១៥ អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្តផាន់លែង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឈួន-ខុក នាមឆាយា ធម្មគុត្តោ កើតឆ្នាំ ១៩២១ អាយុ ២៧ វស្សា ៨ ជាចៅអធិការ វត្តពលព្រីង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ រ័-ហេង នាមឆាយា ចន្ទសិរិ កើតឆ្នាំប អាយុ ២៧ វស្សា ៧ ជាចៅអធិការ វត្តពោធិ៍ ឃុំប្រមេ ស្រុកជាំក្សាន្ត ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៩៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុន-ចិន នាមឆាយា ធម្មសិរិ កើតឆ្នាំរោង អាយុ ៣៣ វស្សា ៧ ជាចៅអធិការ វត្តឈើទាល ឃុំឈើទាល ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៩៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សម-ប៉ក់ នាមឆាយា វិនយត្ថេរ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាចៅអធិការ វត្តអណ្ដូងព្រីង ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៩៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ុង-ធន នាមឆាយា ឧទ្ទត្ថេរ កើតឆ្នាំ ១៩២៤ អាយុ ២៤ វស្សា ៣ ជាចៅអធិការ វត្តក្រែង នៅឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ី-នួន នាមឆាយា វិនយធម្មត្ថេរ កើតឆ្នាំ ១៨៨៣ អាយុ ៥៥ វស្សា ៣៥ ជាចៅអធិការ វត្តក្បាលដំរី ឃុំទំរីង ស្រុកសណ្ដាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥០១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព៉ា-សង់ នាមឆាយា សុវណ្ណសារ កើតឆ្នាំច អាយុ ៥១ វស្សា ៣១ ជាចៅអធិការ វត្តព្រែកណ្ដៀង ឃុំព្រែកណ្ដៀង ស្រុកព្រៃវែង ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥០២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-សៅ នាមឆាយា ពុទ្ធកេសរ កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៥ ជាគ្រូសូត្រស្ដាំ វត្ត-ឃុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ផា-មិន នាមឆាយា ធម្មវិន័យ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ឹម-ហួត នាមឆាយា គន្ធត្ថេរ កើតឆ្នាំរក អាយុ ៥៣ វស្សា ៣២ ជាចៅអធិការ វត្តធម្មនិមិត្ត ឃុំគោកគង់ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥០៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស៊ិវ-គង់ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-រឿង នាមឆាយា សុវណ្ណសរ កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ង់-អ៊ឹម នាមឆាយា គន្ធជោត កើតឆ្នាំមមែ អាយុ ៤២ វស្សា ២២ ជាចៅអធិការ វត្តក្បាលដំរី ឃុំថ្មពួន ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥០៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គាត-ចឹក នាមឆាយា ចិត្តត្ថេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៨ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥០៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ជា នាមធាយា កេសរប្បញ្ញោ កើតឆ្នាំមមី អាយុ ៤៣ វស្សា២៣ ជាគ្រូសូត្រស្តាំ វត្តក្រឡាមាស ឃុំគោក ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥១០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទៀង-នួន កើតឆ្នាំមមី អាយុ ៤៣ វស្សា ២០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល

សញ្ញាប័ត្រលេខ ៥១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទេត-សាក់ នាមធាយា សុវណ្ណកេសរ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៣ ជាគ្រូសូត្រស្តាំ វត្តគោក ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យួ-ទុន នាមធាយា សុវណ្ណធម្មត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៤៤ វស្សា២១ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-អ៊ី នាមធាយា ឧីលបញ្ញោ កើតឆ្នាំកុរ អាយុ ៥០ វស្សា ២៩ ជាគ្រូសូត្រស្តាំ វត្តត្រពាំងថ្នាំង ឃុំព្រាល ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កង-បួរ នាមធាយា ព្រហ្មជោត កើតឆ្នាំច អាយុ ៣៩ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្តត្រពាំង-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ម-ស្តើង នាមឆាយា សីតគុរុ កើតឆ្នាំរកា អាយុ ៤០ វស្សា ១៩ ជាគ្រូសូត្រស្តាំ វត្តពោធិ៍ទង ឃុំកញ្ជៀច ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ឹង-អាន នាមឆាយា សុវណ្ណបញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣៧ វស្សា ១២ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃិត-ថ្វាង នាមឆាយា សទ្ធម្មគុរុ កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តស្វាយរមៀត ឃុំក្តឿងរាយ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥១៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទៀង-សៀម នាមឆាយា គន្ធសារ កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តពោធិវ័ន ឃុំដូង ស្រុក-ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៥១៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កុយ-បែន នាមឆាយា ព្រហ្មសារ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥២០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ូវ-ឈានគី នាមឆាយា ឧត្តមសិរិ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ វត្តសិលានទី ឃុំ-ស្រុកឆ្លូង ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៥២១ ចុះថ្ងៃចន្ទ ១២ កើតខែ មិគសិរ ឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ អ៊ុង-លិន នាមធាយា នាដត្រេះ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១៣ ជាចៅអធិការ វត្តអន្លង់វៀន ឃុំខ្នាច ស្រុក . ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៥២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់-យ៉ត នាមធាយា ចន្ទប្បញ្ញោ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៨ ជាចៅអធិការ វត្តធា ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥២៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ជាន់ នាមធាយា សុវណ្ណសារ កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៦ ជាចៅអធិការ វត្តព្រៃផ្អាវ ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ៥២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ណុប-ទិម នាមធាយា គន្ធប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១២ ជាចៅអធិការ វត្តកំខ្វង ឃុំព្រៃស្លឹក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥២៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ែន អំ នាមធាយា សុវណ្ណត្ថេរ កើតឆ្នាំខាល អាយុ ៥៩ វស្សា ៣៧ ជាចៅអធិការ វត្តកោះចូរាម ឃុំកោះចូរាម ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

សញ្ញាប័ត្រលេខ ១៤ ចុះថ្ងៃចន្ទ ១២ កើតខែមិគសិរឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ និន-ស្តើង នាមឆាយា ផាសពេ កើតឆ្នាំថោះ អាយុ ៣៥ វស្សា ១៤ ជាចៅអធិការ វត្តបេណ្ណពម (ជើងចាប) ឃុំនាម ស្រុកទ្រាំង ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ៥៣០ ចុះថ្ងៃ ១ រោចខែបុស្សឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ អ៊ុក-ទូច នាមឆាយា សុវណ្ណជោត កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១០ ជាចៅអធិការ វត្តឯករង្ស៊ី ព្រែកនរិន្ទ ស្រុក-ខេត្ត បាត់ដំបង ។

សញ្ញាប័ត្រលេខ ៥៣១ ចុះថ្ងៃពុធ ៦ កើតខែបុស្សឆ្នាំជូតសំរិទ្ធិស័ក តាំងលោកគ្រូ សោម-ឃុន នាមឆាយា គន្ធជោត កើតឆ្នាំរោង អាយុ ៦៩ វស្សា ៤៣ ជាចៅអធិការ វត្តអង្គគី ឃុំសិង្ហ ស្រុកសំរោងខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ៥៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-សរ នាមឆាយា បញ្ញាកេសរ កើតឆ្នាំរោង អាយុ ៤៥ វស្សា ២៥ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-ជា នាមឆាយា ជោតិបញ្ញោ កើតឆ្នាំរកា អាយុ ៤០ វស្សា ២០ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ រស់-រ៉ែម នាមធាយា វិនយធម្មោ កើតឆ្នាំមមែ អាយុ ៣០ វស្សា ៩ ជាចៅអធិការ វត្តវិហារខ្ពស់ ឃុំកំពង់ចាស់ ស្រុកឧត្តុង្គ, ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៥៣៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញឹក-កាន នាមធាយា ធន្តគោ កើតឆ្នាំថោះ អាយុ ២២ វស្សា ៣ ជាចៅអធិការ វត្តអន្លង់ក្របី ឃុំក្រាំងបេក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត-កុម នាមធាយា ធម្មសំវរោ កើតឆ្នាំច អាយុ ២៧ វស្សា ជាចៅអធិការ វត្តប្រាង្គណ៍ ឃុំកំពង់ចាស់ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យិម-ហ៊ិន ធម្មគោ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាចៅអធិការ វត្តពោធិ៍ថ្មីព្រៃតាម៉ុក ឃុំជ្រៃ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ទិត--នាង សុវណ្ណគោ កើតឆ្នាំខាល អាយុ ៧១ វស្សា ៥១ ជាចៅអធិការ វត្តសន្តែ ឃុំសាំងឃ្វាង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ប៊ិន ធម្មប្បញ្ញោ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១៤ ជាគ្រូសូត្រស្តាំ វត្តដូនជោក ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៤០. ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ វើត-យ៉ោក យោគត្ថេរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ផេង សុវណ្ណត្ថេរ កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រស្តាំ វត្តត្រពាំងប្រី ឃុំត្របែក ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឡាយ-សំរឹទ្ធ សុវណ្ណកេសរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ា-សេ ព្រហ្មសត្ថា កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៣ ជាចៅអធិការ វត្តស្រយូវ ឃុំស្រយូវ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ វល្លិ៍-ហេង ចន្ទសិរិ កើតឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តទួលអណ្តែត ឃុំព្រះរម ស្រុកជាំក្សាន ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង-មុំ ធម្មប្បញ្ញោ កើតឆ្នាំមមី អាយុ ៥៥ វស្សា ៣៥ ជាគ្រូសូត្រស្តាំ វត្តមុនីរតនារាម ឃុំទៀល ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង-លឿង ធម្មប្បញ្ញោ កើតឆ្នាំម្សាញ់ អាយុ ៤៤ វស្សា ២៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-យិម ធម្មសត្ថា កើតឆ្នាំម្សាញ់ អាយុ ៤៤ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្តទួលអណ្តែត ឃុំទឹកក្រហម ស្រុកជាំខ្សាន ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គិម-ធិក សុវណ្ណកេតុ កើតឆ្នាំរក អាយុ ២៩ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កោត-ជី បទុសុវណ្ណ កើតឆ្នាំ ១៩៤១ វស្សា ៥ ជាចៅអធិការ វត្តខ្សាប់ ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៥៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ប័ន្ន ពុទ្ធសុវណ្ណ កើតឆ្នាំរកា អាយុ ២៨ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្តព្រៃស្រស់ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជា-សឿន ព្រហ្មសរោ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

(មានត)

កំណត់

# ស្នើអំពីរឿងស្ថាបនាវិទ្យាស្ថានមួយ

## សម្រាប់សិក្សាភាសាឥណ្ឌា-ខ្មែរ នៅភ្នំពេញ

**លោកភ៊យ - ប៊ុក ក្រមការក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រែចេញពីបារាំងមកខ្មែរ**

ការសិក្សាភាសាឥណ្ឌាទូទៅ ជាកិច្ចមានប្រយោជន៍ នឹងសារៈសំខាន់ចំពោះប្រទេសកម្ពុជា ដូចគ្នានឹងការសិក្សាភាសាក្រិក - ឡាតាំង ដែលគេដាក់កល់ទុកសម្រាប់និស្សិតរៀនសូត្រ នៅសាលារៀនក្នុងប្រទេសបារាំង, ការចេះដឹងនូវភាសាសំស្ក្រឹតនឹងបាលី ព្រមទាំងអារ្យធម៌ឥណ្ឌា ដែលទាក់ទងដោយអារ្យធម៌នៃប្រទេសជិតខាង ខាងផ្លូវប្រវត្តិសាស្ត្រ ជាកិច្ចគួរបំពេញ ដើម្បីស្រាវជ្រាវនូវទំនៀមទម្លាប់ប្រពៃណីបុរាណខ្មែរ ដែលមានអត្ថដ៏គម្ភីរភាព ហើយនឹងងាយស្វែងរកនូវវត្ថុធាតុ ដែលជាបុព្វហេតុនៃទំនៀមទម្លាប់នោះ ។

ព្រោះហេតុដូច្នេះ ត្រូវតែបណ្ឌិតខ្មែរក្នុងកាលជាអនាគតប្រមូលខ្លួនឲ្យបានច្រើនជាងមុន ដើម្បីនឹងចូលទៅសន្ទនាការអំពីរឿងបូព៌ាវិនិយមរវាងប្រជាជាតិ (l'orientalisme international, មានការសិក្សាខាងភាសាឥណ្ឌាជាកិច្ចត្រូវស្វែងរកដោយពិសេស, បណ្ឌិតទាំងនោះ ក្នុងពេលសន្ទនាការរឿងរ៉ាវក្នុងសាកលលោក អាចឆ្លៀតឱកាសរកផល

ប្រយោជន៍ក្នុងរឿងនោះ ដាក់បញ្ចូលមកក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរបាន លោកអ្នកប្រាជ្ញទាំងប៉ុន្មាន អាចចូលទៅប្រស្រ័យចំពោះកិច្ចការខាងសាលាបារាំងបូព៌ាប្រទេសដែលជាតំណាងក្នុងការស្វែងរកបូព៌ាវិទ្យានិយមជាសាធារណៈ អាចរៀបចំនូវក្រមសញ្ញាតិខ្មែរ ខាងសិលាចារឹកបុរាណវិទ្យា នឹងស្ថាបនានូវមជ្ឈមសិក្សានិស្សិតខ្មែរ ដែលត្រូវយកសាស្ត្រាចារ្យ មានសមត្ថភាព ខាងភាសាឥណ្ឌៀ មកបង្រៀនបានដោយឆាប់រហ័ស ។

ដើម្បីនឹងឧបត្ថម្ភបណ្ឌិតខ្មែរ ដែលពេញចិត្តក្នុងការស្វែងរករឿងនេះ, ប្រទេសបារាំងសែសគួរស្នើចំពោះកម្ពុជរដ្ឋអំពីគ្រោងការស្ថាបនាវិជ្ជាស្ថាននៅក្រុងភ្នំពេញ សម្រាប់សិក្សាឧត្តមវិជ្ជា ដែលគេអាចយកគោលការសិក្សាកិច្ចស្វែងរកភាសាឥណ្ឌៀនៃសាលាឧត្តមវិជ្ជានៅប៉ារីសមកបញ្ចូលផងបាន ។

ការសិក្សានេះ ត្រូវបើកសិទ្ធិឲ្យជនគ្រប់រូបចូលទៅរៀនបានដោយសេរី ឥតមានរើសមុខ, គុណបំណាច់ដែលរៀនក្នុងសាលានោះ ត្រូវបានសញ្ញាប័ត្រមួយដែលនឹងប្រគល់ឲ្យបាន លុះត្រាតែបេក្ខជននោះបានធ្វើកិច្ចការអ្វីមួយដ៏គាប់ប្រសើរ ហើយបានចូលទៅរៀនបណ្ដោះអាសន្ននៅសាលាក្នុងរយៈវេលា ២ ឆ្នាំ ដោយទទួលសេចក្ដីយល់ព្រមពី

គុណៈកម្មការសាលា ដែលបានយករូបបេក្ខជនទៅបង្ហាញចំពោះបាឌហ្វាងសាលានោះ ។

នៅភ្នំពេញ ការសិក្សានេះដែលនឹងធ្វើបាន លុះត្រាតែបាត់បាឌហ្វាងនៃការសិក្សាមួយនាក់ពីប៉ារីស ក្នុងរយៈវេលា ៦ ខែកន្លះ ១ ឆ្នាំ, លេខាធិការដ្ឋានជាអចិន្ត្រៃយ៍ នៃវិជ្ជាស្ថានឧត្តមសិក្សានេះ ត្រូវមានសមាជិកខាងសាលាបូព៌ាប្រទេសម្នាក់មកកាន់ការនៅភ្នំពេញ បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យសម្រាប់ជាមន្ទីរធ្វើការផ្សេងៗ នៃក្រុមនេះ, ប្រាក់ចំណាយក្នុងរឿងនេះ ត្រូវប្រទេសបារាំងសែស និងប្រទេសកម្ពុជាទទួលបន្ទុកជួយគ្នាទៅវិញទៅមក, ប្រាក់បៀវត្សនៃបាឌហ្វាងសាលា ត្រូវប្រទេសបារាំងសែសចេញឲ្យ ចំណែកខាងប្រទេសកម្ពុជា ត្រូវចេញតែខាងប្រាក់ចំណាយសោហ៊ុយសំណាក់អាស្រ័យក្នុងទីនេះ និងថ្លៃយានជំនិះ ។

ចំពោះឆ្នាំ ១៩៥០ ប្រាក់ចំណាយក្នុងរឿងនេះ តាមសេចក្ដីស្មាននៃរាជរដ្ឋាភិបាលខ្មែរប្រហែលជា ៦ - ៧ ម៉ឺនរៀល ។